# ការសំភាសន៏របស់លោកតា ណាយ ធូ

កៈ អ្នកធ្វើការសំភាសន៍ គីម ម៉េង ខៈ អ្នកដែលត្រូវបានគេសំភាសន៍ ណាយ ធូ

## ការសង្ខេបរបស់លោកតា ណាយ ធូ

លោកតា ណាយ ធូ គាត់មានអាយុ ៧៦ ឆ្នាំ ក្នុងឆ្នាំ ២០១៨។លោកតា ណាយ ធូ គាត់មានភេទ ប្រុស។លោកតា ណាយ ធូ មានទីលំនៅនាពេលបច្ចុប្បន្ននៅភូមិកោះដាច់ សង្កាត់ជ្រោយចង្វារ ខេត្ត កណ្តាល។លោកតា ណាយ ធូ បានរៀបអាពាហ៏ពិពាហ៏នៅក្នុងឆ្នាំ ១៩៧០។លោកតា ណាយ ធូ មានកូនចំនួន ៦ នាក់ ស្រី (២នាក់) ប្រុស (៤នាក់)។

កៈ
ចឹងជាដំបូងជំរាបសួរលោកពូខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ធអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៏លោកពូអំពីពង្សប្រវត្តិតតើលោកពូអាយអនុញ្ញាត្តិអោយសំភាសន៏លោកយាយពង្សប្រវត្តិលោកតាបានដែលទេ???

ខៈ បាទបាន ៕

កៈ
ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៏លោកពូគឺជាថ្ងៃទី១៩ខែ០៥(ឧសភា)ឆ្នាំ២០១៨ហើយធ្វើការសំភាសន៏ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៏លោកពូឈ្មោះណាយ ធូ
ចឹងផ្តើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះរបស់លោកតាបានដែលទេលោកតាគឺជាឈ្មោះពេញរបស់លោកតាម៉ងហាសលោកតា ???

ខៈ បាទបានខ្ញុំឈ្មោះរបស់ខ្ញុំនឹងគឺនាមត្រកូលរបស់ខ្ញុំនឹងគឺ ណាយ ធូ នឹងហាសហើយប្រសិនជានាមត្រកូលរបស់ឪពុករបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថាសុខ ណាយ
បាទហើយនិយាយទៅយើងចេះតែតគ្នាចឹងហាសបាទហើយនឹងគឺឈ្មោះនឹងអស់ត្រឹមឪពុករបស់ខ្ញុំចឹងហាសបាទពីព្រោះអីនឹងឪពុករបស់គាត់នឹងគឺគាត់មានឈ្មោះសុខ ហើយសំរាប់គាត់ឈ្មោះ ណាយ
ហើយសំរាប់មកដល់ជំនាន់ខ្ញុំនឹងគឺខ្ញុំបានដាក់ឈ្មោះរបស់ឪពុករបស់ខ្ញុំនឹង ណាយធូ នឹងតែម្តងបាទ ៕

កៈ
បាទហើយចឹងបាននិយាយថាលោកតាបានយកឈ្មោះរបស់ឪពុកនឹងមកដាក់មែនដែលទេលោកតា???

ខៈ បាទបាទត្រូវហើយបាទ៕

ក៖
បាទហើយចឹងអរគុណច្រើនលោកតាបាទហើយចឹងសំរាប់លោកតាឆ្នាំនឹងថាតើលោកតាមានអាយុប៉ុន្មានឆ្នាំហើយលោកតា???

ខ៖ បាទសំរាប់ខ្ញុំឆ្នាំនឹងគឺខ្ញុំមានអាយុ ៧៦ ឆ្នាំ ហើយបាទ៕

ក៖
បាទហើយចឹងសំរាប់លោកតាមានទីកន្លែងកំណើតនឹងនៅទីកន្លែងណាដែលទៅលោកតា???

ខ៖ បាទសំរាប់ខ្ញុំមានទីកន្លែងកំណើតនឹងនៅស្រុកកំណើតនៅ ភូមិល្វា ឃុំ កោះដាច់ ស្រុកមុខកំពូល ខេត្តកណ្ដាល
បាទហើយនឹងនិយាយពីដើមចឹងហាសបាទគឺមានតែប៉ុននឹងបាទ៕

ក៖
បាទអរគុណច្រើនលោកតាបាទហើយចឹងសំរាប់សព្វថ្ងៃនឹងឪពុករបស់លោកតាគាត់រស់នៅមានជីវិតដែលរឺទេលោកតា???

ខ៖
បាទសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់បានស្លាប់តាំងពីនៅក្នុងជំនាន់ពោលពតមកម្លេះបាទហើយសំរាប់ឪពុករបស់ខ្ញុំនឹងសុខ ណាយ គឺគាត់បានស្លាប់ទាំងឪពុកហើយនឹងម្ដាយម្លេះបាទ៕

ក៖
បាទហើយចឹងសំរាប់ឪពុកហើយនឹងម្ដាយរបស់លោកតាគាត់មានឈ្មោះអ្វីដែលទៅលោកតា???

ខ៖ បាទហើយសំរាប់ឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា តា ណាយ នឹងគឺជាឪពុកបង្កើតរបស់ខ្ញុំហាសបាទហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា យាយរឿន ហើយសំរាប់គាត់ឈ្មោះពេញរបស់គាត់គឺ យឹម រឿន ហើយសំរាប់តាណាយនោះវិញឪពុករបស់គាត់មានឈ្មោះថា សុខ ណាយ
ហើយសំរាប់ម្ដាយខាងរបស់ឪពុកខ្ញុំនឹងគឺគាត់មានឈ្មោះថា សឹម រឿន
បាទហើយនឹងគាត់ខាងម្ដាយរបស់ខ្ញុំនឹងហាសបាទ
ហើយសំរាប់ខាងឪពុករបស់ខ្ញុំនឹងគឺគាត់មានឈ្មោះ សុខ ណាយ
បាទហើយដល់មកដល់ត្រកូនមកដល់ខ្ញុំនឹងគឺបានដាក់ឈ្មោះថា ណាយ ធូ បាទ៕

ក៖
បាទហើយចឹងប្រសិនជាឪពុកហើយនឹងម្ដាយរបស់លោកតាគាត់នៅរស់វិញថាតើគាត់មានអាយុប៉ុន្មានឆ្នាំហើយទៅលោកតា???

ខៈ បាទប្រសិនជានិយាយទៅប្រសិនជាគាត់មានជីវិតនៅរស់នឹងចូលជិត ១០០ឆ្នាំហើយបាទនិយាយទៅចូល ៩៧ឆ្នាំ រឺក៏៩៨ឆ្នាំអីនឹងបាទពីព្រោះអីនឹងគឺខ្ញុំបានរៀបអាពាហ៍ពិពាហ៍នៅក្នុងឆ្នាំ ១៩៧០ហាសបាទបាទហើយសំរាប់ឆ្នាំ ១៩៧០នឹងគឺអាយុរបស់ឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងចូលក្បែល៥០ឆ្នាំជាងហើយបាទបាទហើយសំរាប់ឆ្នាំ ១៩៧០ នឹងគឺស្រុកកំណើតរបស់ខ្ញុំនឹងគឺនៅល្វាឯនោះបាទនិយាយទៅគឺនៅកោះនឹងដែលចឹងហាសបាទនិយាយទៅកោះនៅទីនោះមួយហើយនឹងកោះនៅទីនោះមានមួយដែលចឹងហាសហើយនិយាយទៅគឺនៅចុងកោះនឹងហាសហើយសំរាប់ខ្ញុំនឹងស្រុកខាងលោកយាយរបស់ខ្ញុំនឹងគឺនៅខាងលិចនឹងហាសហើយសំរាប់ខ្ញុំនៅខាងកើតនេះវិញចឹងហាសបាទក៏ប៉ុនតែកាល់នៅក្នុងជំនាន់នោះសំរាប់ឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងគឺគាត់មានដីធ្លីនៅក្បាលកោះមានច្រើនណាស់បាទដែលវានៅជាប់ឆ្នេរខ្សាច់នឹងហាសបាទហើយសំរាប់ដីខាងប្រពន្ធរបស់ខ្ញុំនឹងនៅខាងចាប់ពីផ្លូវនេះទៅចឹងហាសទៅចឹងទៅគឺវានៅទល់មុខគ្នាចឹងហាសបាទហើយសំរាប់ផ្លូវនឹងគឺវានៅផ្លូវថ្នលជាតិចឹងហាសបាទពីនឹងទៅដល់មាត់ទន្លេរនឹងហាសបាទហើយដល់ពេលចឹងហើយដីរបស់ឪពុករបស់ខ្ញុំនឹងគឺវាទៅដល់ចាស់ឬស្សីនឹងទៅដល់កោះបាទនិយយាទៅវាទៅដល់ក្រោយហាសខាងក្រោយឬស្សីបាទនិយាយទៅដីដុះដល់ណាគឺវាដល់នឹងហើយបាទចឹងហើយបានខ្ញុំនឹងហើយនឹងប្រពន្ធរបស់ខ្ញុំនឹងបានរៀបអាពាហ៍ពិពាហ៍បានគ្នាជាប្ដីហើយនឹងប្រពន្ធនឹងគ្នាតែម្ដងហាសបាទហើយកូនមានចំនួន៦នាក់ដូចគ្នាបាទ៕

កៈ
បាទហើយចឹងខ្ញុំចង់សួរលោកតាបក់ក្រោយបន្តិចថាតើទីកន្លែងកំណើតរបស់ឪពុកហើយនឹងម្ដាយរបស់លោកតាគាត់មានទីកន្លែងកំណើតនៅកន្លែងណាដែលទៅលោកតា???

ខៈ
បាទសំរាប់ទីកន្លែងកំណើតរបស់ឪពុករបស់ខ្ញុំនឹងគឺគាត់នៅស្រុកល្វាគឺនៅលើទឹកដីកោះដាច់នឹងហាសបាទនិយាយទៅគឺវានៅជាមួយនឹងគ្នាចឹងហាសគ្រាន់តែថាយើងនៅទីនេះគេបានហៅថាស្រុកល្វាហើយសំរាប់នៅខាងនោះគឺគេបានហៅស្រុកកោះដាច់ចឹងហាសបាទក៏ប៉ុនតែវានៅផ្ទះនឹងវានៅជួបគ្នាចឹងហាសបាទ៕

កៈ
បាទហើយចឹងសំរាប់ឪពុកហើយនឹងម្ដាយរបស់លោកតាគឺនៅទឹកដីកោះដាច់នឹងជាមួយនឹងគ្នាតែម្ដងមែនដែលទេលោកតា???

ខៈ
បាទសំរាប់ឪពុកហើយនឹងម្ដាយរបស់ខ្ញុំគឺគាត់រស់នៅទឹកដីកោះដាច់នឹងជាមួយនឹងគ្នាតែម្ដងបាទ៕

កៈ
បាទហើយចឹងសំរាប់សព្វថ្ងៃនឹងថាតើលោកតាមានបងប្អូនចំនួនប៉ុន្មាននាក់ដែលទៅលោកតា???

ខៈ
បាទសំរាប់សព្វថ្ងៃនឹងខ្ញុំដែលបងប្អូនដែលបានស្លាប់ហើយរឺក៏ទាំងស្លាប់ទាំងរស់គឺខ្ញុំមានបងប្អូនចំនួន ៧ នាក់បាទ៕

កៈ បាទហើយចឹងសំរាប់លោកតាបានចាំឈ្មោះរបស់គាត់ទាំងអស់ដែលរឺទេលោកតា???

ខៈ បាទប្រសិនជានិយាយទៅគឺចាំឈ្មោះនឹងគឺខ្ញុំចាំទាំងអស់ដែលចឹងហាសបាទ៕

កៈ
បាទហើយចឹងសំរាប់លោកតាអាចប្រាប់ឈ្មោះរបស់បងប្អូនរបស់លោកតាម្តងម្នាក់ម្តងម្នាក់បានដែលទេហើយសំរាប់ទីមួយគាត់មានឈ្មោះអ្វីដែលទៅលោកតា???

ខៈ បាទសំរាប់បងប្អូនរបស់ខ្ញុំទី១គាត់មានឈ្មោះថា សុខ យិន
ហើយសំរាប់បងប្អូនរបស់ខ្ញុំទី២គាត់មានឈ្មោះថា ណាយ ធូ គឺខ្ញុំតែម្តងបាទ
ហើយសំរាប់បងប្អូនរបស់ខ្ញុំទី៣គាត់មានឈ្មោះថា ណាយ ថោង
ហើយសំរាប់បងប្អូនរបស់ខ្ញុំទី៤គាត់មានឈ្មោះថា ណាយ ណាន
ហើយសំរាប់បងប្អូនរបស់ខ្ញុំទី៥គាត់មានឈ្មោះថា ណាយ គ្រប់
ហើយសំរាប់បងប្អូនរបស់ខ្ញុំទី៦គាត់មានឈ្មោះថា ណាយ យ៉ាត
ហើយសំរាប់បងប្អូនរបស់ខ្ញុំទី៧គាត់មានឈ្មោះថា ណាយ ចាប
បាទទាំងអស់មានចំនួន៧នាក់ក៏ប៉ុនតែមាននាក់ដែលនៅរស់មានជីវិតនឹងនៅសល់តែ៤នាក់នោះទេគឺមានប្រុស២នាក់ហើយនឹងស្រី២នាក់ចឹងទាំងអស់មាន៤នាក់បាទក៏ប៉ុនតែអ្នកដែលនៅរស់នៅនឹងគឺគេរស់នៅស្រុកថៃឯនោះបាទនឹងស្រីហាសបាទហើយសំរាប់មួយទៀតនៅល្វានឹងប្រុសហាសបាទហើយមួយនៅល្វាហើយមួយទៀតគឺនៅនឹងបាទ៕

កៈ
បាទហើយចឹងសំរាប់បងប្អូនរបស់លោកតាគឺពួកគាត់រស់នៅផ្សេងគ្នាទាំងអស់មែនដែលទេលោកតា???

ខៈ បាទសំរាប់បងប្អូនរបស់ខ្ញុំនឹងគឺរស់នៅផ្សេងគ្នាទាំងអស់គ្នាបាទ៕

កៈ
បាទហើយចឹងសំរាប់សព្វថ្ងៃថាតើកូនរបស់លោកតាមានចំនួនប៉ុន្មាននាក់ដែលទៅលោកតា???

ខ៖
បាទសំរាប់កូនរបស់ខ្ញុំមានកូនចំនួន៤នាក់ក៏ប៉ុនតែគឺគេបានស្លាប់អស់១ហើយហើយល្មវនឹងគឺនៅសល់តែ៣នាក់នោះទេបាទហើយកូនរបស់ខ្ញុំដែលបានស្លាប់នឹងគឺគេនៅព្រែកជញ្ជៃងចឹងហាសគឺនៅខាងភ្នំពេញហើយសំរាប់មួយទៀតនឹងផ្ទះរបស់វានឹងនៅខាងសៀមរាបនឹងផ្ទះរបស់វានឹងហាសហើយសំរាប់មួយទៀតគឺនៅនឹងតែម្តងហាសបាទ៕

ក៖
បាទហើយសំរាប់កូនរបស់លោកតាសព្វថ្ងៃគាត់កំពុកសិក្សារឺក៏កំពុកធ្វើការងារដែលទៅលោកតា???

ខ៖
បាទសំរាប់កូនរបស់ខ្ញុំនឹងគឺមិនបានធ្វើការងារអ្វីទេគឺពួគគាត់សុទ្ធតែមានគ្រួសារអស់ហើយនឹងហើយម្នាក់ម្នាក់សុទ្ធមានកូនចំនួន៣នាក់រឺក៏៤នាក់អស់ហើយនឹងបាទហេហេហេ៕

ក៖
បាទហើយចឹងសំរាប់កូនរបស់លោកតាមានកូន៣នាក់រឺក៏៤នាក់នឹងចឹងសំរាប់លោកតាមានចៅទាំងអស់មានចំនួនប៉ុន្មាននាក់ដែលទៅលោកតា???

ខ៖
បាទសំរាប់ខ្ញុំនឹងគឺខ្ញុំមានចៅច្រើនណាស់បាទហើយសំរាប់ចៅរបស់ខ្ញុំនៅខាងនោះមានចំនួន៥នាក់ហើយសំរាប់នៅខាងព្រែកជញ្ជៃងនឹង៥នាក់នាក់ដែលចឹងហាសបាទហើយសំរាប់ចៅដែលនៅខាងនៅសៀមរាបនឹងប្រុស៣នាក់ហើយនឹងស្រី១នាក់ទៀតមានចំនួន៤នាក់ទៀតបាទហើយនៅទីន្លែងនេះមានចំនួន៣នាក់ទៀតទាំងអស់សរុបទៅ១២នាក់បាទហើយសំរាប់ចៅទាំងនៅទីនោះ៥នាក់ទៀតហើយនឹងភ្នំពេញទៀតចឹងទាំងអស់មានច្រើននាក់ខ្លាំងណាស់បាទក៏ប៉ុនតែសំរាប់ជីវិតរបស់ខ្ញុំនឹងគឺកំសត់ខ្លាំងណាស់បាទសំរាប់ម្តាយហើយនឹងឪពុកគឺគាត់ទាំង២នាក់ល្អខ្លាំងណាស់បាទនិយាយទៅគឺគាត់ល្អខ្លាំងណាស់ហើយសំរាប់កូនទាំងអស់គឺពួកគាត់សុទ្ធតែដើលតាមគុណលងធម៏ហាសបាទហើយសំរាប់ប្អូនប្រុសរបស់ខ្ញុំមួយនឹងនៅពេលដែលវាបានរៀបអាពាហ៍ពិពាហ៍នឹងគឺថាគឺឪពុកហើយនឹងម្តាយរបស់ខ្ញុំនឹងគឺគាត់បានចាយដីធ្លីអោយចឹងហាសដីនៅខាងលិចនឹងហើយសំរាប់ការងាររបស់វានឹងគឺវាមិនខំប្រឹងធ្វើការងារនោះទេគឺវាខំប្រឹងតែផឹកស៊ីហើយនឹងសប្បាយហើយសំរាប់លុយនឹងគឺវាមិនដែលសល់នោះទេបាទហើយនៅពេលដែលវាបានផឹកស៊ីយូរចឹងទៅវាទៅជាឆ្កួតហើយនឹងវាបានមើលទៅឡប់ដែលគេបាននិយាយថាមិនជាសូវដឹងអីចឹងហាសបាទហើយនៅពេលនឹងគឺវានឹងផឹក៏បានលង់ទឹកនឹងស្លាប់ចឹងទៅបាទ៕

ក៖
បាទហើយចឹងម្នាក់ដែលលោកតាបានប្រាប់ខ្ញុំថាគាត់នឹងបានស្លាប់នឹងមែនដែលទេលោកតា???

ខ៖
បាទនឹងហើយម្នាក់ដែលខ្ញុំបានប្រាប់ក្មួយឯងនឹងហាសបាទហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបានប្រាប់វាដែលចឹងហាសក៏ប៉ុនតែនឹងដូចថាយើងនឹងប្រាប់វានឹងគឺមិនបានតែម្តងបាទនឹងទី១ហាសបាទហើយសំរាប់ទី២នឹងគឺប្អូនប្រុសរបស់ខ្ញុំដែលប្រសិនជានិយាយពីដើមនឹងគឺដូចជាសំពត់នៅក្នុងភ្នុកតែម្តងហើយនិយាយទៅគឺគាត់នឹងល្អណាស់ហើយគឺគ្រាប់លក្ខណះរបស់ដូចមនុស្សស្រីចឹងហាសបាទហើយសំរាប់ម្នាក់នៅពេលដែលមានប្តីហើយនឹងប្រពន្ធនឹងវាទៅជាឆ្កួតអស់ទៅចឹងគឺវាបានដើលលេងដើលស៊ីដើលផឹកហើយមានស្រីញីចឹងហាសហើយនៅពេលដែលវាបានកូនក្រមុំរបស់គេនឹងគឺគេមិននឹងមិនមែនជាកូននាក់ក្រទេណានិយាយទៅគឺគេបានកូនប្រធានភូមិនៅព្រៃកញ្ចែងហើយសំរាប់ផ្ទះរបស់គេនឹងពិនសាលារបស់លោកហាសនិយាយធំណាស់បាទហើយសំរាប់កូនស្រីរបស់គេនឹងគឺកូនពៅតែមួយទៀតណាស់បាទ៕

ក៖
បាទហើយចឹងអរគុណាច្រើនលោកតាហើយចឹងខ្ញុំចង់សួរលោកតាមួយទៀតថាតើសំរាប់ភរិយារបស់លោកតាគាត់មានឈ្មោះអ្វីដែលទៅលោកតា???

ខ៖ បាទសំរាប់ភរិយារបស់ខ្ញុំគាត់មានឈ្មោះថា ឡឹក រស់ ៕

ក៖ បាទហើយសំរាប់ភរិយារបស់លោកតាគាត់មានអាយុប៉ុន្មានឆ្នាំហើយលោកតា???

ខ៖ បាទសំរាប់ប្រពន្ធរបស់ខ្ញុំគាត់មានអាយុ ៦៥ ឆ្នាំហើយបាទ៕

ក៖
បាទហើយចឹងបានន័យថាប្រពន្ធរបស់លោកតាគាត់អាយុប្អូនលោកតា២ឆ្នាំមែនដែលទេលោកតា???

ខ៖ បាទនិយាយទៅគឺគាត់ប្អូនខ្ញុំនឹង ២ ឆ្នាំពីព្រោះអីនឹងគឺគាត់ ឆ្នាំ មរមី ហើយសំរាប់ខ្ញុំ ឆ្នាំ ម្សាញ់ ៕

ក៖
បាទហើយចឹងសំរាប់ទីកន្លែងកំណើតរបស់ភរិយារបស់លោកតាគាត់នៅទីកន្លែងណាដែលទៅលោកតា???

ខ៖
បាទសំរាប់ស្រុកកំណើតរបស់ភរិយារបស់ខ្ញុំនឹងគឺគាត់នៅទីកន្លែងនឹងដែលចឹងហាសបាទហើយសំរាប់ភូមិនឹងគឺគេបានហៅថាភូមិក្បាលកោះស្រុកមុខកំពូលហើយដល់ពេលខេត្តគឺជាខេត្តកណ្តាលហើយសំរាប់ល្វេនឹងគឺគេបានកែប្រែហើយចឹងហាសគឺគេបានហៅកន្លែងនឹងថាភូមិក្បាលកោះស្រុកមុខកំពូលខណ្ឌជ្រោយចង្វារវិញម្តងបាទ៕

កៈ
បាទហើយចឹងបានន័យថានៅកន្លែងនឹងកាត់ចូលភ្នំពេញហើយមែនដែលទេលោកតា???

ខៈ
បាទទីកន្លែងនឹងគឺគេបានកាត់ចូលភ្នំពេញហើយបាទហើយគេបានកាត់ចូលខណ្ឌជ្រោយចង្វារនឹងចូលមកដល់ភ្នំពេញហើយបាទហើយសំរាប់ចាញ់ថ្នល់កែងចឹងហាសបាទ៕

កៈ
បាទហើយចឹងនៅពេលដែលលោកតាបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភរិយារបស់លោកតាថាតើលោកតារៀបអាពាហ៍ពិពាហ៍ដោយសេចក្ដីស្រលាញ់រឺក៏មានឪពុកហើយនឹងម្ដាយបង្ខំលោកតា???

ខៈ
បាទនៅពេលដែលខ្ញុំបានរៀបអាពាហ៍ពិពាហ៍នឹងគឺដោយឪពុកហើយនឹងម្ដាយរបស់ខ្ញុំចឹងហាសពីព្រោះអីនឹងប្រសិនជានិយាយពីដើមនឹងគឺយើងមិនបានចេះស្រលាញ់នោះទេបាទគឺយើងមិនបានចេះស្រលាញ់ស្រីយ៉ាងមិចនោះទេបាទ៕

កៈ
បាទហើយចឹងសំរាប់លោកតាធ្វើយ៉ាងមិចដែលទៅបានជួយជាមួយនឹងលោកយាយដែលទៅលោកតា???

ខៈ
បាទសំរាប់ឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងគឺគាត់បានមើលឃើញគាត់ល្អហើយចឹងទៅហើយម្យ៉ាងទៀតពួកគាត់បានគិតថានៅពេលដែលយើងអោយយកប្រពន្ធដែលនៅជិតគ្នាចឹងទៅនៅពេលដែលកូនបានមកចឹងគឺកូនរបស់យើងនឹងចេះជួយមើលដីគ្នាហើយនឹងការពារគ្នាបានចឹងហាសបាទហើយនឹងមើលការខុសត្រូវបាទនឹងហើយជាមូលហេតុដែលខ្ញុំនឹងជាប់ជាមួយនឹងប្រពន្ធរបស់ខ្ញុំចឹងបាទហើយសំរាប់ប្រពន្ធរបស់ខ្ញុំនឹងផ្ទះរបស់គាត់គឺនៅឆ្ងាយណាស់គឺមិនមែននៅទីន្លែងនឹងនោះទេបាទនិយាយទៅឆ្ងាយពីទៅប្រហែលជា ១៣ គីឡូរទៅចុះ
១៣គីឡូររឺក៏១៤គីឡូរហាសបាទគឺគាត់រស់នៅពាក់កណ្ដាលពាក់កណ្ដាលកោះចឹងហាសបាទហើយសំរាប់ពាក់កណ្ដាលកោះនឹងវាបណ្ដាយ ៧រឺក៏ ៨គីឡូរហើយនិយាយទៅ ២៤ គីឡូរទៅចុះប្រហែលហាសបាទនិយាយទៅវាឆ្ងាយដែលចឹងហាសហើយដល់ឆ្ងាយចឹងទៅក៏បានអោយគាត់រស់នៅទីកន្លែងនឹងហើយយើងមានដីធ្លីហើយនឹងទ្រព្យសម្បត្តិចឹងទៅបាទ៕

កៈ
បាទហើយចឹងនៅពេលដែលលោកបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភរិយារបស់លោក

តាហើយចឹងសំរាប់លោកតាហើយនឹងលោកយាយរស់នៅការពារដីធ្លីនឹងចំការនឹងជាមួយនឹងគ្នាមែនដែលទេលោកតា???

ខ៖
បាទនៅពេលដែលខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភរិយាខ្ញុំគឺខ្ញុំនឹងភរិយារបស់ខ្ញុំនឹងរស់នៅហើយនឹងការពារជាមួយនឹងគ្នាចឹងទៅបាទ៕

ក៖
បាទហើយចឹងខ្ញុំចង់សួរលោកតាមួយសំណួរទៀតកាល់ដែលលោកតាបានបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភរិយារបស់លោកតានឹងថាតើលោកតាបានរៀបអាពាហ៍ពិពាហ៍នឹងនៅទីកន្លែងណាហើយស្រុកអ្វីហើយនឹងភូមិអ្វីខេត្តអ្វីដែលទៅលោកតា???

ខ៖
បាទនៅពេលដែលខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភរិយាខ្ញុំនឹងគឺនៅទៅកន្លែងនឹងឯងបាទបាទសំរាប់នៅក្នុងជំនាន់នឹងប្រសិនជាយើងនិយាយទៅគឺនៅក្នុងឆ្នាំ ១៩៧០ នឹងគឺជារដ្ឋប្រហារហាសបាទហើយសំរាប់នៅក្នុងជំនាន់នឹងគឺគេបានយក ៧០០០ បាទ គឺ ៧០០០រៀល៕

ក៖ បាទហើយសំរាប់ ៧០០០នឹងគឺជាថ្លៃបណ្ដាលការមែនដែលទេលោកតា???

ខ៖ បាទទាំងអស់នឹងគឺជាបណ្ដាលការបាទ៕

ក៖
បាទហើយចឹងសំរាប់លោកតាបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភរិយាលោកតានឹងគឺនៅក្នុងឆ្នាំ ១៩៧០ នឹងមែនដែលទេលោកតា???

ខ៖ បាទសំរាប់ខ្ញុំនឹងគឺបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភរិយាខ្ញុំនឹងនៅក្នុងឆ្នាំ ១៩៧០ នឹងហាសបាទហើយសំរាប់ក្មួយឯងនឹងបានកើតទាន់ដែលតាមែនដែលទេក្មួយបាទហើយនៅពេលដែលខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភរិយាខ្ញុំនឹងគឺបានរយះពេល២ឆ្នាំបានខ្ញុំមានកូនចឹងហាសបាទហើយនៅពេលដែលខ្ញុំនឹងបានរស់នៅទីកន្លែងនឹងបាទហើយនៅដល់ពេលចូលឆ្នាំរដ្ឋប្រហារនឹងគឺឆ្នាំរដ្ឋប្រហារនឹងគឺគេបានជំលាស់យើងនឹងបានចេញពីកោះនឹងហាសបាទគឺខ្ញុំដើលមិនរួចនោះទេតែគេបានជំលាស់យើងនឹងបានចេញពីកោះនឹងនិយាយទៅគឺខ្ញុំវេទនាណាស់ហើយប្រសិនជានិយាយពីប្រវត្តរបស់ខ្ញុំនឹងគឺខ្ញុំវេទនាខ្លាំងណាស់បាទហើយនៅពេលដែលគេបានជំលាស់យើងបានចេញពីកោះនឹងហើយគឺគេបានអោយយើងនឹងទៅរស់នៅផ្សារព្រែកលាភអូនឯងស្គាល់ផ្សារព្រែកលាភនឹងដែលទេក្មួយបាទហើយសំរាប់ផ្សារព្រែកលាភនឹងគឺនៅក្បែរផ្សារនឹងគឺនៅជិតវត្តនឹងតែម្ដងហាសបាទដល់ពេលចឹងគឺខ្ញុំបានទៅរកមួយបាទគឺទៅរកគេបានដើម្បីមកដឹងយើងចឹងបាទដើម្បីដឹងយើងនឹងទៅបាក់ខែងហើយសំរាប់កន្លែងនឹងគឺគេបានហៅ១២រឺក៏១៣អីនឹងរបស់គេនឹងហាសបា

ទហើយសំរាប់នៅក្នុងជំនាន់នឹងគឺជាជំនាន់ពោលពតនឹងហាសគឺគេបានគៀលខ្ញុំចេញទៅគឺគេបានចាប់ខ្ញុំទៅហើយនៅពេលដែលគេបានចាប់នឹងគឺមិនមែនចាប់ខ្ញុំតែម្នាក់នោះទេគឺគេបានចាប់ច្រើនគ្នាណាស់គឺមានចំនួន២០០នាក់រឺក៏៣០០នាក់ហាសបាទហើយក្មួយអើយប្រសិនជានិយាយពីត្រីវិញគឺត្រីច្រើនណាស់ដូចត្រីជាគេបានបែកផ្កាហាសបាទនឹងគឺត្រីហាសនឹងគឺយើងនិយាយពីត្រីហាសហើយសំរាប់ខ្ញុំនឹងគឺមិននិយាយកហុសក្មួយឯងនោះទេហើយសំរាប់ត្រីស្ដោកនឹងគឺបិនបិនភ្លៅហាសហើយនៅពេលដែលគេបានចាប់នឹងបានដាក់មោងនឹងគឺមានគីឡូប្រហែល៤គីឡូរឺក៏៥គីឡូហាសបាទហើយសំរាប់យើងគឺយើងមិនអាចទៅចាប់វាបាននោះទេនិយាយទៅគឺពីមោងនឹងហាសហើយប្រសិនជាយើងចង់បានចឹងតរតែយើងនឹងត្រូវយកពង់នឹងទៅតាមហើយប្រសិនជាយើងត្រូវចាប់នឹងមោងននឹងហាសបានយើងចាប់បានហាសបាទហើយយើងត្រូវតែវៃវាបានត្រីបាទហើយសំរាប់ត្រីនឹងគឺជាត្រីស្ដិនហាសបាទហើយសំរាប់ត្រីនឹងគឺបិនជញ្ជិងនឹងហាសហើយសំរាប់ត្រីផ្ទាប់នឹងបិនបិនបាត់ដៃរបស់យើងចឹងហាសបាទហើយសំរាប់ត្រីរាយអាត្រីរាយដែលមានរាងតូចតូចនឹងគឺគេមិនបានយកនោះទេគឺគេនឹងបានបោះវាចោលចឹងហាសបាទហើយនៅពេលដែលនឹងគឺគេបានជំលាស់ខ្ញុំនឹងទៅហើយនៅពេលដែលគេបានជំលាស់ខ្ញុំទៅហើយចឹងទៅរហូតដល់វត្តស្រែ ១០០ ហាសហើយសំរាប់ក្មួយឯងនឹងបានស្គាលវត្តស្រែ ១០០
ដែលរឺទេនឹងហើយដល់វត្តស្រែ ១០០
ហើយនៅពេលដែលយើងបានទៅដល់ហើយចឹងគឺគេបានដាំបាយហើយសំរាប់អ្នកណាដែលត្រីមួយរឺក៏មានត្រី២ចឹងទៅគឺយើងយកទៅចូលហើយនឹងដាំបាយជាមួយនឹងគេគ្នាចឹងទៅហាសពីព្រោះអីនឹងគឺយើងមានគ្នាច្រើនណាស់បាទហើយដល់ពេលនឹងយើងបានលឺគេនិយាយគ្នាថាពួកអាមេរិចកាំងមកហើយចឹងហាសហើយនៅពេលនឹងគេបានអោយយើងបានឡើងមកទៀតហើយហើយសំរាប់យើងហូបបាយនឹងគឺមិនទាន់បានត្រង់មាត់ផងនឹងហាសហើយគឺគេបានអោយយើងដើលទៅទៀតហើយហើយគេបានអោយយើងនឹងឡើងទៅទៅដល់ថ្នល់កែងហាសហើយសំរាប់ផ្លូវនឹងគឺមានរាងកោងចឹងហាសហើយនៅពេលដែលយើងបានឡើងទៅដល់ផ្ទះនឹងគឺថាគេនៅមានអាស្តុងដែលនៅសល់ពីជំនាន់ថៅកែដែលពួកគេបានហៅថាពួកផ្កាយព្រឹកហាសបាទហើយសំរាប់គាត់នឹងគឺជាថៅកែកាប៉ាល់គឺគេថៅកែកាណូកបាទហើយនៅពេលដែលយើងបានទៅដល់នឹងហើយចឹងគឺគេបានអោយយើងនឹងឡើងទៅចឹងហាសហើយនៅពេលដែលគេបានអោយយើងបានឡើងហើយចឹងគឺគេបានមានកាំភ្លើងនឹងចុះមកចឹងហាសហើយប្រសិនជាយើងនឹងចង់ឡើងចុះនឹងគឺយើងត្រូវតែសុំគេចឹងហាសបាទហើយប្រសិនជាយើងមិនបានសុំគេចឹងគឺគេនឹងតាមយើងចឹងហាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបានរស់នៅទីកន្លែងនឹងបានរយះពេល៧ថ្ងៃដែលចឹងហាសហើយសំរាប់នៅទីកន្លែងនឹងគឺថាយើងនឹងត្រូវតែសុំគេដូចជាការបង់ស្រុងចឹងហាសបាទហើយសំរាប់អ្នកដែលគេមានធូធារនឹងក៏គេបានមកបង់ដែលចឹងហាសបាទហើយនៅពេលដែលគេបានបង់ស្រុងនឹងគឺគេមានទៅគ្រាប់កន្លែងចឹងហាសបាទហើយគែបានមកអោយមកវិញខ្លះចឹងហាសបាទហើយសំរាប់គេខ្លះនឹងគឺគេបានអោយលុយចឹងហាសបាទហើយដល់ពេលចឹងទៅគឺខ្ញុំបានរស់នៅកន្លែងនឹងបានចំនួន១សប្ដាហ៏ហើយនៅពេលដែលខ្ញុំបានរស់នៅនឹង

ចំនួន១សប្តាហ៍ចឹងទៅគឺពួកទាហ៊ានខាងយើងនឹងគឺជាទាហ៊ានខាងលុនណននឹងហាសបាទហើយនៅពេលនឹងគឺពួកខាងទាហ៊ានខាងខ្មែរក្រហមនឹងគឺគេបានគៀលយើងចឹងហាសហើយនៅពេលដែលគេបានគៀលយើងនឹងគឺគេបានគៀលយើងនឹងទៅខាងអាការកោងហើយនិយាយទៅក្មួយអើយគ្រាន់តែយើងនឹងបានទៅដល់នឹងគឺគេបានអោយយើងនឹងបានឡើងចឹងគឺមានទាហ៊ាននឹងបានឡើងមកពោធយើងនឹងតែម្តងហើយសំរាប់ពួកនឹងគឺវាមិនបានហ៊ានចូលមកខាងក្នុងនោះទេបាទហើយសំរាប់ពួកវានឹងគឺវាបានឈរនឹងខាងមាត់ទន្លេរនឹងហើយពួកវានឹងបានប្លោងចូកមកខាងក្នុងចឹងហាសបាទក៏ប៉ុនតែនៅពេលដែលពួកវាបានប្លោងនឹងគឺវាប្លោងនឹងមិបានត្រូវចឹងហាសបាទហើយនៅពេលដែលវាប្លោងមកហើយនឹងគឺមិនបានត្រូវអាផ្ទះនឹងតែវាមកត្រូវអាកំផែងអារបង់ខាងអាការកោងចឹងហាសបាទហើយនៅពេលដែលប្លោងមកនឹងគឺវាបាក់រើលទាំងអស់ហើយសំរាប់អាកំផែងដែលនៅខាងរបង់នឹងគឺវាបានបាក់ហើយនឹងរាបដល់ដីតែម្តងហាសបាទហើយដល់ពេលព្រឹកប្រលឹមឡើងចឹងទៅគឺគេបានជំលាល់ខ្ញុំនឹងឡើងទៀតគឺឡើងរហូតដល់វៃមាន់១០ហាសបាទនិយាយទៅគឺទៅខាងផ្លូវជួរនោះចឹងហាសបាទគឺគេបានហៅកន្លែងនឹងថាជួរមេមាត់ហាសគឺមេមាត់ជុមស្លូងហាសបាទគឺគេបានអោយខ្ញុំនឹងទៅកន្លែងនឹងបាទហើយនៅពេលដែលខ្ញុំនឹងបានទៅដល់កន្លែងនឹងគឺថាក្មួយអើយវេទនាខ្លាំងណាស់ក្មួយអើយនិយាយពីថាស្លឹកត្រប់ចេកណាវ៉ារបស់យើងនឹងហាសគឺយើងបានបេះហូបហើយទាំងអស់នឹងនិយាយថាពីឆ្ងាញ់ណាស់ហើយមានរស់ជាតិផ្អែមដូចស្ករចឹងហាសបាតហើយនៅពេលនឹងគឺថាវាឆ្ងាញ់ចឹងហាសបាទហើយសំរាប់ដំបូងនឹងគឺគេបានអោយយើងនឹងបានបាយសំរាប់ហូបចឹងហាសហើយនៅពេលដែលគេបានអោយបាយយើងសំរាប់ហូបចឹងគឺដូចជា២ក្អែងចឹងហាសបាទហើយនៅពេលនឹងគឺយើងបានកាប់ស្លឹងចេកនឹងក្រាលហើយយើងបានក្រាលនឹងអិតហើយនឹងថ្មចឹងទៅហើយយើងក៏បានចាក់ចឹងទៅហើយនៅពេលដែលយើងបានចាក់ហើយចឹងគឺយើងគ្មានស្លាបព្រាមកពីណាបាទហើយយើងមានអំបិលនឹងចំនួនមួយក្តាបហើយនឹងផ្លែពៅរបស់គេចឹងទៅហើយនឹងមានត្រសក់ច្រូសចឹងទៅហាសបាទហើយសំរាប់ត្រសក់របស់គេនឹងហើយដល់ពេលនឹងហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងវេទនាណាស់ហើយសំរាប់គេបានសួរមកកាន់ខ្ញុំចឹងហាសគឺគេបានសួរយើងនឹងពីប្រវត្តិរបស់យើងថាយើងនឹងពីមុខនឹងគឺយើងបានធ្វើការងារអ្វីគេខ្លះចឹងហាសបាទហើយគេសួរយើងនឹងថាប្អូនឯងវីក៏ក្មួយឯងចឹងទៅហាសបាទហើយប្រសិនជាអោយគេធ្វើជាគ្រូវីក៏អ្នកគ្រូនឹងគឺខ្ញុំនឹងអោយគាត់នឹងបានជួយខ្ញុំនឹងបានចឹងហាសបាទគឺជួយយើងនឹងបង្រៀនយើងដូចគាត់គឺជាអ្នកចេះដឹងចឹងទៅហាសបាទពីព្រោះអីគឺដើម្បីទុកួអោយកូនចៅជំនាន់ក្រោយចឹងទៅហាសបាទគឺចេះមួយចឹងមួយចឹងទៅបាទមានឯណាគ្រាន់តែព្រលឹមឡើងគ្រាន់តែគេបានលឺឈ្មោះអ្នកគ្រូហើយនឹងឈ្មោះអ្នកដែលធ្វើការងារនឹងបាននបន្តិចនឹងគឺគេបានយកទៅទាំងអស់គឺគេបានយកទៅវៃជាមួយនឹងខ្នងពូថៅហើយនៅពេលដែលគេបានវៃនឹងគឺមិនមែនពោលជំលាសទេណាស់បាទហើយសំរាប់ជំនាន់នឹងគឺគេបានវៃដោយជាមួយនឹងអុសចឹងហាសបាទនិយាយទៅគឺគេបានវៃចោលទាំងអស់នឹងបាទហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមិនបានធ្វើអ្វីគេនោះទេគឺខ្ញុំរត់តែរម៉ក់នោះទេបាទហើយសំរាប់រម៉ក់ពីដើមនឹងហាសគឺខ្ញុំបានរត់រម៉ក់ជើងអារម៉ក់កងយើងនឹងហាសបាទបា

ទសំរាប់ក្មួយឯងបានស្គាល់ហើយដល់ពេលចឹងទៅគេក៏បានសួរមកកាន់ខ្ញុំថាសំរាប់ខ្ញុំមានឪពុកហើយនឹងម្ដាយហើយនឹងបងប្អូនដែលជាប់ជាសាច់ញ្ញាត្តិដែលរស់នៅក្នុងស្រុកនឹងដែលរឺទេបាទហើយសំរាប់ឪពុកក្មេករបស់ខ្ញុំនឹងគឺគេបានជំលាស់គាត់នឹងបានមកមុនបាទគឺគាត់បានរស់នៅស្រុកនឹងហាសបាទហើយប្រសិនជាមានឪពុកក្មេកនឹងគឺអោយគាត់នឹងមកជួបនឹងយើងមកចឹងហាសបាទហើយនៅពេលនឹងសំរាប់ឪពុកក្មេករបស់ខ្ញុំនឹងគឺគាត់បានមកជួបនឹងគេចឹងហាសហើយនៅពេលដែលគាត់បានមកជួបចឹងហើយគឺគាត់បានមកសួរថាសំរាប់តាឯងនឹងហ៊ានលត់ចូលភ្លើងដែលរឺទេគឺគេបាននិយាយចឹងហាសបាទហើយនៅពេលនឹងគឺគាត់បាននិយាយថាគឺខ្ញុំថាហ៊ានហើយប្រសិនជាហ៊ានបានខ្ញុំអោយនឹងបានទៅចឹងហាសហើយប្រសិនជាមិនហ៊ានទេគឺខ្ញុំមិនបានអោយកូននឹងបានទៅនោះទេបាទហើយនៅពេលនឹងគឺឪពុកក្មេករបស់ខ្ញុំនឹងគឺគាត់ហ៊ានពីព្រោះពួកគាត់ខ្លាចយើងរត់ចឹងហាសហើយសំរាប់ផ្លូវនឹងគឺជាផ្លូវច្រក់ចេញផ្លូវច្រក់ចូលហើយនៅពេលនឹងគឺគេបានពញ្ញាក់យើងចឹងហាសហើយសំរាប់គេគឺគេបានអោយខ្ញុំនឹងនៅយាមហើយនៅពេលដែលខ្ញុំនៅយាមនឹងគឺខ្ញុំយាមឡើងសោមចឹងហាសហើយសំរាប់អ្នកដែលយាមផ្សេងនឹងគឺគេមានល្បិចច្រើនដែលចឹងហាសពីព្រោះអីគេរត់ចេញជាទាហ៊ានផ្លូវច្រក់ចេញផ្លូវច្រក់ចូលហើយនៅពេលនឹងមកគឺគេបានរត់ចូលជាទាហ៊ានចឹងហាសបាទហើយនៅពេលដែលយើងបានរត់ចូលធ្វើជាទាហ៊ាននឹងគឺគេនឹងសំលាប់យើងចោលចឹងហាសនិយាយសំលាប់ទាំងអស់ទាំងអស់តែម្ដងចដូចថាមួយពូជមួយពូជទាំងអស់តែម្ដងហាសបាទពីព្រោះអីប្រសិនជាយើងរត់ចូលធ្វើទាហ៊ាននឹងគឺគេនឹងសំលាប់យើងចោលទាំងអស់ចោលបាទហើយដល់ពេលចឹងទៅសំរាប់ខ្ញុំនឹងគឺក៏បានយកប្រពន្ធចឹងទៅហាសរហូតដល់ស្រុកនឹងបានបែកភ្នំពេញចឹងហាសហើយនៅពេលដែលបានបែកភ្នំពេញនឹងគឺយើងនឹងបានជួបនឹងគ្នាហើយសំរាប់យើងបានដើលតាមរកគ្នានៅគ្រាប់ទីកន្លែងនឹងហើយបានយើងនឹងរត់តាមមកនឹងរស់នៅកោះនឹងវិញចឹងហាសបាទហើយនៅពេលដែលយើងបានមករស់នៅកោះនឹងហើយចឹងទៅហើយយើងទាំងអស់គ្នានឹងទាំងប្រពន្ធកូនខ្ញុំនឹងក៏មានម្ដាយធម៌នៅលើកោះនឹងហាសបាទហើយនៅពេលដែលយើងបានមករស់នៅលើកោះនឹងគឺយើងមានគេអាណិតយើងចឹងហាសហើយនៅពេលដែលគេបានអាណិតយើងហើយចឹងគេបានចង់លើកកូននឹងអោយយើងទៀតចឹងហាសហើយសំរាប់ខ្ញុំនឹងបាននិយាយថាខ្ញុំមិកយកនោះទេប្រសិនជាខ្ញុំយកទាល់តែខ្ញុំនឹងសួរប្រពន្ធរបស់ខ្ញុំសិនហាសបាទហើយយ៉ាងមិចយ៉ាងមិចទាល់តែជួបផ្ទាល់នឹងបានបានពីព្រោះអីនឹងគឺខ្ញុំនឹងមិនមែនជាមនុស្សដែលមានស្រីញ្ញីអីនោះទេកាល់នៅក្នុងជំនាន់នឹងហាសបាទហើយវាមិនដូចក្មេងល្ងូវនឹងនោះទេមានមនុស្សស្រីច្រើនចឹងហាសបាទហេហេហេហេ៕

ក៖

បាទចឹងអរគុណាច្រើនលោកតាចឹងខ្ញុំចង់សួរលោកតាបក់ក្រោយបន្តិចថាតើសំរាប់លោកតាមានបានរៀនរឺក៏បានសិក្សាអីដែលរឺទេលោកតាដែលនៅក្នុងជំនាន់ពោលពតហាសបាទគឺជាជំនាន់ដែលរដ្ឋប្រហារថាតើលោកតាមានសិក្សាអីដែលរឺទេលោកតា???

ខ៖
បាទសំរាប់នៅក្នុងជំនាន់ពោលពតនឹងមែនដែលទេក្មួយបាទសំរាប់ជំនាន់រដ្ឋប្រហារនឹងគឺខ្ញុំនឹងមិនបានរៀនហើយនឹងសិក្សាអ្វីនោះទេបាទក៏ប៉ុនតែនឹងសំរាប់នៅក្នុងជំនាន់នឹងគឺគេបានជំលាស់ខ្ញុំនឹងទៅកន្លែងនឹងគឺខ្ញុំមិនបានរៀនអ្វីនោះទេបាទពីព្រោះអីនឹងនៅក្នុងជំនាន់នឹងគឺខ្ញុំមានប្តីប្រពន្ធហើយចឹងហាសហើយនៅពេលដែលខ្ញុំមានប្តីហើយនឹងប្រពន្ធហើយចឹងគឺគេបានជំលាស់ខ្ញុំហើយនៅពេលដែលខ្ញុំបានជំលាស់ខ្ញុំហើយចឹងគឺគេបានអោយខ្ញុំនឹងឡើងត្នោតចឹងហាសបាទហើយសំរាប់ខ្ញុំនឹងគឺខ្ញុំមានសាច់សរស្អាតដូចក្មួយឯងចឹងហាសបាទហើយសំរាប់ខ្ញុំនឹងគឺនៅក្នុងជំនាន់នឹងគឺខ្ញុំជាក្មេងច្រលើមដែលចឹងហាសកាល់នៅក្នុងជំនាន់នឹងហើយនៅពេលដែលខ្ញុំនឹងក៏បានឆ្លើយតបនឹងគេថាតាំងពីកើតពីពោះម្តាយរបស់ខ្ញុំមកគឺខ្ញុំនឹងមិនដែលបានស្គាល់ដើមត្នោតនឹងយ៉ាងមិចនោះទេបាទហើយប្រសិនជាអោយខ្ញុំទៅឡើងដើមត្នោតនឹងគឺខ្ញុំមិនចេះឡើងនោះទេដាច់ខាតគឺខ្ញុំមិនឡើងនោះទេបាទនៅពេលដែលខ្ញុំនិយាយចឹងអាងតែខ្ញុំនឹងវាមិនអីនោះចេះតែនិយាយទៅចឹងហាសបាទហើយនៅពេលដែលនឹងគឺគេអោយខ្ញុំឡើងដើមត្នោតនឹងតតែបានចឹងហាសបាទហើយនៅពេលដែលខ្ញុំបានឡើងដើមត្នោតនឹងគឺខ្ញុំបានធ្លាក់ពីចុងត្នោតចុះមកហើយនៅពេលដែលខ្ញុំបានធ្លាក់ចុះមកចឹងគឺខ្ញុំនឹងបានសន្លប់អស់រយះពេល១ថ្ងៃនឹង១យប់ហាសបាទហើយនៅពេលដែលសំរាប់ខ្ញុំនឹងគឺខ្ញុំស្ទើលតែស្លាប់ហើយគេបានស្ងោរទាហើយនឹងស្ងោរមាន់ហើយសំរាប់ខ្ញុំប្រកាច់ប្រកិនចឹងហាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងនៅស្រុកកន្លែងហាសបាទហើយសំរាប់ភូមិគឺភូមិឈើទារហាសបាទហើយនិយាយទៅគឺវេទនាណាស់ហើយដល់ពេលចឹងទៅគឺគេបានអោយខ្ញុំនឹងបានសំរាក់ហើយនៅពេលដែលខ្ញុំបានសំរាក់ហើយចឹងគឺខ្ញុំបានធូចឹងហាសហើយនៅពេលដែលខ្ញុំបានធូហើយគឺគេបានអោយខ្ញុំសំរាក់បានតែមួយសប្តាហ៍នោះទេបាទហើយពេលនឹងគឺគេបានអោយខ្ញុំនឹងទៅឡើងដើមត្នោតទៀតហាសបាទហើយនៅពេលដែលខ្ញុំបានឡើងហើយចឹងគឺខ្ញុំនៅតែមិនដឹងថាគេគៀបត្នោតវាយ៉ាងមិចទៀតដែលចឹងហាសបាទហើយមិនដឹងថាគេបានគៀបយ៉ាងមិចហើយគេដាក់នៅក្នុងបំពង់នឹងយ៉ាងមិចគឺយើងមិនចេះតែម្តងហាសបាទពីព្រោះអីនឹងគឺយើងធ្លាប់បានឃើញដែលក៏ប៉ុនតែយើងបានឃើញគេធ្វើទាំងអស់នឹងតែពីចំងាយចឹងហាសបាទហើយសំរាប់ត្នោតរបស់ខ្ញុំវាមានដែលក៏ប៉ុនតែខ្ញុំបានជូលអោយអ្នកស្រែចឹងដើមឡើងចឹងហាសបាទហើយសំរាប់ដើមត្នោតរបស់ខ្ញុំនឹងគឺមាន៣០ដើមរឺក៏៤០ដើមចឹងហាសបាទហើយដើមត្នោតទាំងអស់នឹងគឺខ្ញុំជូលអោយអ្នកស្រែគេបានឡើងចឹងទៅហើយដល់ពេលចឹងទៅគឺខ្ញុំនឹងក៏ចេះហើយដឹងពីរបៀបឡើងដើមត្នោតចឹងទៅគៀបហើយសំរាប់អាត្នោតសំរាប់ផ្ការបស់គឺទង់របស់មិនចឹងបាទហើយសំរាប់ផ្ការបស់វាមាន៣រឺ៤ចឹងហាសបាទហើយវាមានក្មេងផ្កាចឹងទៅហើយសំរាប់យើងមិនចេះចឹងគឺយើងបានទៅគៀបគ្រាប់ផ្កាទាំងអស់ចឹងហាសហេហេហេហេបាទគឺមិនចេះទេមើលគ្រាន់តែគេមិនបានគៀបចឹងនោះទេបាទមើលតែផ្កានឹងវាមាន៥ទង់ចឹងគឺគេបានទុក្ខផ្កា២នឹងចឹងទៅគឺគេគៀបតែផ្កាតែ៣នោះទេបាទនឹងសំរាប់តែផ្កា២ទេហាសបាទហើយសំរាប់ផ្កាទាំង៥នឹងកាល់ដែលយើងគៀបផ្កាទាំង៥នឹងគឺវាចេញទឹកទាំង៥ផ្កានឹងដែលបាទក៏ប៉ុនតែវាបានតែកន្លះបំពង់នោះទេបាទហើយសំរាប់ផ្កា២នឹងគឺគេបានគៀបដែលតែវាបានចេញទឹកនឹងជាងកន្លះបំព

ង់គឺវាទៅចឹងវិញរួចដល់ពេលយើងមិនចេះហើយសំរាប់គេចេះមែនទែនវិញគឺគេមិនបានគៀបផ្កា២នោះទេគឺគេគៀបតែផ្កា១នោះទេបាទអាទង់មួយនឹងគឺគេបានកាច់ចោលទាំងចឹងហាសហើយគេទុក្ខអាមួយដែលនៅចំកណ្ដាលចឹងហាសបាទគឺគេបានកាច់ចោលអស់និយាយទៅគឺគេបានទុក្ខតែផ្កា២នឹងគឺកាច់ចោលទាំងអស់ចឹងហាសបាទពីព្រោះអីវាមាន២ទង់ចឹងហាសបាទហើយសំរាប់២ទង់នឹងមានផ្កា១០គឺវាកាច់តែផ្កា២នឹងហើយវាបានទុក្ខហើយចងរួមគ្នាចឹងទៅហើយស្ទូកចូលប្រហែលជាបិននឹងមានផ្កា២ចឹងទៅបាទហើយសំរាប់ការស្ទូកនឹងវាស្រួលចឹងហាសហើយតាំងពីពេលនឹងគឺខ្ញុំបានចេះដូចគេដូចឯងចឹងទៅបាទហើយនៅពេលដែលយើងបានចេះចឹងទៅគឺគេបានដាក់កំណត់អោយយើងបានឡើងបាទហើយសំរាប់គេក្នុងមួយថ្ងៃនឹងគឺគេបានអោយយើងឡើងបានក្នុង១ថ្ងៃនឹងអោយគេបានាចំនួន២ខ្ទះអោយគេបាទក្នុងការឡើងនឹងហាសក៏ប៉ុនតែនៅពេលដែលខ្ញុំឡើងនឹងក្នុង១ថ្ងៃនឹងគឺខ្ញុំឡើងបានក្នុងការកំណត់របស់វានឹងបាន១ពាងព្រែកអង្គរហើយសំរាប់ខ្ញុំនឹងគឺខ្ញុំឈរទេបាទហើយនៅពេលនឹងគេអោយខ្ញុំកូរនឹងក្នុងមួយថ្ងៃនឹង៥០ខ្ទះហាសបាទក៏ប៉ុនតែនឹងគឺគេបានចាក់ចឹងហាសក៏ប៉ុនតែប្រសិនជាអ្នកដែលនៅរស់នៅគឺមានតែអ្នកដែលរស់នៅឡើងដើមត្នោតនោះទេបាទហើយក្រៅពីអ្នកដែលឡើងដើមត្នោតនឹងគឺគេបានស្លាប់ទាំងអស់នឹងបាទពីព្រោះអីនឹងគឺមានអ្នកខ្លះនឹងគឺគេមានសេរីខ្លះចឹងហាសសេរីនឹងបានន័យថានៅពេលដែលយើងបានសំរាក់ពីការឡើងត្នោតហើយចឹងហើយយើងអាចដើលចែកបាយអីចឹងហាសបាទហើយសំរាប់ម្ហូបហើយនឹងបាយអីនឹងគឺយើងអាចហូបបានដោយសេរីចឹងហាសបាទរួចហើយសំរាប់ស្ករអីអីនឹងហើយនឹងផ្លែត្នោតនឹងក៏យើងអាចហូបបានដោយសេរីដែលបាទហើយសំរាប់ត្រីហើយនឹងសាច់នឹងគឺយើងបានហូបបានដោយសេរីដែលចឹងហាសបាទក៏ប៉ុនតែដូចថានៅពេលដែលយើងបានទៅរកត្រីបានចំនួន១០អីចឹងទៅហើយយើងក៏បានដាក់រួមគ្នារីក៏ដាក់លើសពីគេចឹងទៅហាសបាទគឺគេបានដាក់ទាំងអស់ហើយយើងទុក្ខតែមួយរីក៏២អីចឹងទៅហើយយើងលាក់ទុក្ខអោយប្រពន្ធហើយនឹងកូនរបស់យើងចឹងទៅហាសបាទហើយសំរាប់មួយនឹងគឺយើងអាចលួចលាក់បានចឹងហាសបាទហើយប្រសិនជាយើងរកបានត្រីចំនួន១០ហើយយើងមកអោយប្រពន្ធហើយនឹងកូនរបស់យើងទាំង១០នឹងគឺមិនបាននោះទេបាទហើយប្រសិនជាយើងលាក់គឺយើងនឹងត្រូវជាប់នៅនឹងតែម្ដងបាទហើយសំរាប់ក្នុង១ថ្ងៃនឹងគឺយើងត្រូវតែចេញស្ករអោយគេនឹងចំនួន១តោនហាសនិយាយទៅគឺជាង១តោនហាសបាទ៕

ក៖
បាទហើយចឹងឡើងក្នុង១ថ្ងៃនឹងឡើងបានប៉ុន្មានដើមបានក្នុងមួយថ្ងៃនឹងបានស្ករចំនួន១តោនចឹងលោកតា???

ខ៖
បាទនិយាយទៅគឺយើងទាំងអស់គ្នាឡើងត្នោតនឹងគឺច្រើនគ្នាណាស់គឺយើងឡើងចំនួន៥០នាក់ឯងនោះទេបាទហើយសំរាប់៥០នាក់នឹងគឺនៅក្នុងក្រុមនឹងមានចំនួន ៥០ នាក់បាទហើយសំរាប់៥០នាក់នឹងគឺគេបានចាប់រួចជាស្រេចហើយចឹងហាសបាទនឹងនៅក្

ងមួយក្រុមហាសហើយគឺគេបានចាក់សំរាប់អ្នកឯងថាសំរាប់
១០នាក់ខាងផ្នែកកាប់អូសចឹងទៅ ហើយសំរាប់ខាង ៥នាក់នេះខាងផ្នែកដុតភ្លើងស្ករ
ហើយសំរាប់៥០នាក់ទៀតនឹងគឺសំរាប់តែខាងផ្នែកឡើងតែត្នោតនោះទេបាទ
ហើយសំរាប់អា៥នាក់ទៀតខាងផ្នែកលាងតែបំពង់នោះទេនិយាយទៅគឺគេបានចាក់អោយ
យើងនឹងធ្វើការងាររួចជាស្រេចហើយនៅពេលដែលគេបានមកចឹងទៅគេរ៉ែកហើយយកម
កដាក់ឈូសឈូសឈូសហើយចឹងទៅសំរាប់អ្នកណាដែលលាងបំពង់លាងបំពង់ចឹងទៅ
បាទនឹងសំរាប់នៅម៉ុម៉ុរបស់យើងចឹងហាសបាទរួចហើយសំរាប់ស្ករនឹងយើងជឿរថាសំរាប់
ក្មួយឯងនៅក្នុងក្រុមណាហើយនឹងនៅសហករមួយណាហើយយើងទៅសុំស្គាល់គេចឹងទៅ
ឧទាហរណ៍ថាយើងនឹងស្គាល់ស្ករនឹងចំនួនប៉ុន្មានហាសឧទាហរណ៍ថាចំនួន
១០០គីឡូរហើយយើងដូសអោយគេនឹងចំនួន
១០០គីឡូរចឹងទៅបាទនឹងខាងសហករក៏នឹងហើយសំរាប់សហករក៏ខាងផ្សេងនឹងគឺគេបានស្គា
ល់ ២០០ គីឡូរចឹងទៅគឺយើងដូសអោយគេនឹងចំនួន ២០០
គីឡូរចឹងទៅបាទហើយមានពិបាក់នឹងទៅទិញដូរអីកាល់នៅក្នុងជំនាន់នឹងបាទហើយនៅ
ពេលដែលគេបានមកត្រូវការអីនឹងគឺគេនឹងមកយកហើយមកបាច់មានការទិញដូរអីនោះទេ
បាទនឹងគឺវាចឹងហាសបាទ៕

កៈ
បាទហើយចឹងនៅពេលដែលលោកតាបានធ្វើស្ករត្នោតចឹងថាតើលោកតាបានហូបឆ្អែតដែ
លរឺទេលោកតា???

ខៈ
បាទប្រសិនជានិយាយពីរឿងស្ករនឹងគឺសំរាប់ខ្ញុំនឹងគឺខ្ញុំបានហូបបានឆ្អែតឆ្អនហាសបាទហើ
យនឹងបានហូបបានបរិបូរទៀតហាសបាទពីព្រោះអីនឹងសំរាប់យើងនឹងបានរស់នៅទីកន្លែង
នឹងហើយចឹងគឺយើងចេះតែលួចលាក់១០គីឡូរហើយនឹង២០គីឡូរនឹងយើងចេះតែលួចលា
ក់ចឹងទៅហាសបាទនិយាយទៅប្រសិនជាយើងធ្វើអ្វីគឺយើងនឹងហូបនឹងហើយបាទក៏ប៉ុនតែ
សំរាប់នៅក្នុងជំនាន់នោះទេប្រសិនជាខ្ញុំនឹងនិយាយទៅគឺខ្ញុំប្រាប់ក្មួយឯងចឹងហាសបាទសំ
រាប់អ្នកដែលឡើងត្នោតនឹងគឺសុទ្ធតែជាអ្នកមហារសេដ្ឋីហើយបាទហើយសំរាប់ទាំងអស់នឹ
ងគឺគេសុទ្ធតែអ្នកជំនាញហាសហើយសំរាប់អ្នកដែលនៅខេត្តពោតធិ៍សាត់នឹងហាសហើយ
សំរាប់គាត់នឹងគឺជាអ្នកមានហើយគឺជាអ្នកថៅកែពេជ្រនឹងហាសបាទហើយអ្នកមានដែល
មាននៅក្នុងខេត្តពោតធិ៍សាត់នឹងហាសបាទហើយប្រសិនជានិយាយមិនមានយ៉ាងមិចពី
ព្រោះអីនឹងសំរាប់ស្ករតែមួយគីឡូរនឹងប្តូរយកមាសចំនួន១ជីបានហាសបាទហើយមានពេ
លខ្លះនឹងសំរាប់ស្ករមួយគីឡូរនឹងប្តូរយកមាសមួយខ្សែហាសបាទហើយយកទៅណាទេហើ
យសំរាប់ខ្សែករនឹងមាសគឺបិនម្រាមដៃរបស់យើងចឹងហាសធំណាស់បាទហើយសំរាប់មា
សខ្លះនឹងគឺយកមកពាក់អោយឆ្កែចឹងទៅហើយមានពេលខ្លះនឹងសំរាប់ឆ្កែនឹងយកមកគៀប
ហើយនឹងពាក់អោយឆ្កែហើយនឹងចងអោយឆ្កែទៀតបាទហើយសំរាប់នៅក្នុងជំនាន់នឹងគឺ
សំរាប់មាសនឹងគឺគ្មាននាក់ចង់បាននោះទេសំរាប់មាសបាទហើយសំរាប់ទឹកត្នោតនឹងតែមួ

យបំពង់នឹងគឺគេបានប្តូរយកមកខ្សែករនឹងមួយខ្សែចឹងទៅហើយសំរាប់នាឡិការ៉ាយ៉ង់រ៉ាដូរ
ហាសរ៉ាដូរអីរ៉ាយ៉ងស៊ីស្សែននឹងហាសបាទមួយនឹងគឺទឹកត្នោតមួយបំបង់តែប៉ុននឹងបាទនិ
យាយទៅគឺពួកអានាឡិការអាថ្លៃអារ៉ាដូរហាសបាទរ៉ាដូរអីរ៉ាយ៉ងស៊ីស្សែនគឺវាមានតម្លៃថ្ងៃ
ណាស់បាទហើយសំរាប់ទាំងអស់នេះនឹងគឺសុទ្ធពួកវាបាទពីព្រោះអីនឹងកាល់នៅក្នុងជំនាន់
នឹងសំរាប់អ្នកដែលឡើងត្នោតនឹងម្នាក់ម្នាក់សុទ្ធតែអ្នកមានហាសបាទក៏ប៉ុនតែសំរាប់នៅក្នុ
ងជំនាន់នឹងគឺគេបានជំលាស់ហើយសំរាប់នៅក្នុងជំនាន់នឹងគឺយើងខ្លាចគឺខ្លាំងណាស់បាទ
ហើយសំរាប់និយាយថាគេយក១០បំពង់ចឹងទៅយើងយកបានតែ៥បំពង់ចឹងហាសបាទនិ
យាយទៅគឺជាកន្លែងរបស់គេចឹងទៅគឺគេទុក្ខកន្លែង៥បំពង់ផ្ទះរបស់គេចឹងទៅហាសបាទ
ហើយសំរាប់គេគឺគេលួចលាក់នៅក្នុងផ្ទះរបស់គេហើយគេលុកលៃហើយយើងស្គាល់គេចឹង
ហាសពីព្រោះអីសំរាប់យើងគឺជាអ្នកមកពីចំងាយផងចឹងហាសបាទហើយសំរាប់នៅក្នុងម្នា
ក់នឹងក៏មានមាសនឹងនៅក្នុងខ្លួននឹងចំនួន១គីឡូរមាសដែលចឹងហាសបាទនិយាយទៅអ្វីក៏
ដោយគឺសុទ្ធតែប្តូរដែលបាទហើយចុះក្មួយឯងគិតមើលប្រសិនជាយើងមិនប្តូរចឹងចឹងយើង
ទុក្ខអោយស្លាប់មែនដែលរឺទេបាទហើយយ៉ាងណាប្រសិនជាយើងបានប្តូរចឹងក៏យើងអាច
បានរស់នៅបានមួយម៉ោងដែលហាសបាទនឹងហើយហើយសំរាប់មុនដំបូងនឹងអាមួយដែ
លបានស្លាប់នឹងហាសបាទមុនដំបូងនឹងគេបានគ្រាន់តែសែនហើយនឹងដុសនោះទេហើយ
នៅពេលដែលដុសហើយចឹងគឺយកទៅបោះចោលចឹងទៅនិយាយទៅគឺបោះចោលដូចឆ្កែចឹ
ងហាសបាទនិយាយទៅដូចឆ្កែដូចឆ្មាចឹងហាសបាទហើយសំរាប់កន្លែងដែលខ្ញុំបានទៅនឹង
គឺមានគ្នាចំនួន ៣០០ នាក់បាទហើយសំរាប់
៣០០នាក់គឺមាន៣ការដ្ឋានហាសបាទហើយនៅក្នុងមួយការដ្ឋាននឹងមានមនុស្សចំនួន
១០០នាក់នឹងនៅក្នុងមួយការដ្ឋានហាសបាទពីមុនដំបូងនឹងមានមនុស្សនឹងចំនួន ៣០០
នាក់ហើយដល់ពេលយូរយូរទៅនៅសល់តែមនុស្ស ២០០នាក់
អស់ចឹងហាសហើយសំរាប់រាល់ដង់នឹងក្នុង១ការដ្ឋានធ្លាប់មានមនុស្សចំនួន ១០០នាក់
ដល់ពេលនឹងក្នុងការដ្ឋាននៅសល់តែ ៥០នាក់
ហើយនឹងនៅ៤០នាក់ហើយដល់ពេលយូរយូរទៅក្នុងមួយការដ្ឋាននឹងនៅសល់មនុស្ស
២០នាក់រឺក៏៣០នាក់បាទហើយនៅពេលដែលនៅសល់មនុស្សតិចពេកចឹងទៅក៏គេបានមក
បង្រួម៣ការដ្ឋាននឹងមកនៅតែមួយការដ្ឋាននោះទេបាទនឹងដល់ពេលដែលយើងមកនិយា
យពីមនុស្សដែលស្លាប់វិញម្តងហាសបាទហើយសំរាប់អ្នកដែលបានស្លាប់នឹងសំរាប់មុនដំបូ
ងនឹងគឺគេបានលីយកទៅនឹងហាសបាទដ៏ពេលយូរយូរទៅគឺវាមិនបានលីនោះទេហើយសំ
រាប់មនុស្សដែលបានស្លាប់នឹងហាសបាទហើយដល់អ្នកដែលបានរស់នៅក្នុងរោងនឹងស្លាប់
ម្តង២នាក់មានពេលខ្លះនឹងស្លាប់៣នាក់ចឹងទៅគឺពួកគេបានដេកស្តុតស្តើងហើយគេក៏បាន
ស្លាប់ចឹងទៅហាសបាទហើយអ្នកដែលបានយាមនឹងក៏បានដើលទៅមើលនៅរោងផ្សេង
ផ្សេងនឹងថាតើមានមនុស្សណាដែលគេបានស្លាប់ទៀតដែលរឺទេហើយមានរោងខ្លះនឹងគឺគេ
បានស្លាប់៥នាក់អីចឹងទៅហើយសំរាប់រោងខ្លះមាន៣នាក់អីចឹងទៅគេក៏បានដាក់នៅលើរ
ទះក្របីរបស់យើងនឹងហាសបាទហើយដល់ពេលនឹងគឺគេបានលើកបោះលើកបោះចឹងទៅ
៥នាក់៥នាក់រឺក៏៦នាក់អីចឹងទៅបានហើយបានគេដឹកយកទៅចាក់ចោលនៅក្នុងរុនដៅរប

ស់គេដែលបានជីកដាក់ម្តងអីចឹងទៅបាទបាននិយាយទៅគឺវាវេទនាណាស់ហើយប្រហារសែនវេទនាណាស់បាទហើយសំរាប់មនុស្ស៣០០នាក់រហូតមក១០០នាក់ហើយរហូតនៅសល់មនុស្សតែ៣០នាក់អីនឹងនោះទេបាទគ្មានសល់អ្វីគឺគ្មានសល់នោះទេបាទហើយនិយាយទៅគឺវេទនាណាស់គឺមហារវេទនាណាស់ហើយសំរាប់ឪពុកហើយនឹងម្តាយនឹងគឺបានស្លាប់ទាំងអស់នឹងបាទគឺគ្មានសល់នោះទេបាទហើយសំរាប់ឪពុកហើយនឹងម្តាយរបស់ខ្ញុំនឹងគឺគាត់ទាំង២នាក់នឹងគឺគាត់ចង់រត់ទៅរស់នៅខេត្តបាត់ដំបងឯងនោះទេបាទហើយសំរាប់ឡានរបស់គឺគេរត់មកនៅកោះនឹងដែលចឹងហាសហើយនិយាយទៅតាំងពីថ្នល់កែងព្រែកព្នៅហើយនឹងព្រែកតាមែកហើយនឹងតាមជួរមាត់ទន្លេរនឹងទាំងអស់នឹងនិយាយទៅទាំងកោះទាំងអស់នឹងតែម្តងហាសបាទហើយវាបានចាញ់បោកតាំងពីនឹងទៅហាសនឹងសំរាប់ខ្ញុំនឹងហាសដែលបានចាញ់បោកគេហើយនៅពេលដែលខ្ញុំនឹងបានចាញបោកគេដែលគេបាននិយាយសំរាប់កាប៉ាល់របស់គេចឹងហាសបាទហើយនៅម្តុំអារវត្តិទាក់នឹងហើយគេបាននៅលើទឹកដែលទឹកនឹងវានៅក្បែរផ្លូវចឹងហាសបាទហើយសំរាប់កាប៉ាល់ដែលគេបានដាក់នៅក្នុងទឹកនឹងគឺគេបាននិយាយថានែមមិត្តយើងទាំងអស់គ្នាដែលអ្នកមានកង់ហើយនឹងមានខោមានអាវហើយនឹងមានទ្រព្យសំម្បត្តិអីទាំងអស់នឹងយកមកដាក់នៅកាប៉ាល់នៅខាងនេះហាសបាទហើយសំរាប់អ្នកកាប៉ាល់នឹងគឺគេចេះទៀតអាអ្នកដែលគេបានកាន់ម៉ាកស៊ីននឹងគឺគេបានយកក្រណាត់យកមកបង់ខ្លីបជិតនៅលើម៉ាស៊ីននឹងហាសបាទហើយសំរាប់នឹងគឺគេបានដាក់ចឹងលឺស្ងធឹងហេហេហេហេហើយនៅពេលនឹងគឺខ្ញុំបានចាញ់បោលគេហាសបាទហើយសំរាប់កាប៉ាល់មួយនោះមានម៉ាស៊ីនបាទហើយនិយាយទៅតាំងពីអីវ៉ាន់របស់យើងទាំងអស់តាំងពីទូរតាំងពីវិទ្យុហើយនឹងមានចានការដាបមាសនិយាយទៅគឺទាំងអស់នឹងសុទ្ធតែល្អល្អណាស់បាទហើយបារហើយនឹងកង់ចាស់ចាស់នឹងគឺយើងទុក្ខដាក់ខោអាវអីចឹងហាសបាទយើងបានដាក់នៅលើកាប៉ាល់នឹងទាំងអស់រួចហើយសំរាប់ការប៉ាល់នឹងគឺបានបញ្ឆេះម៉ាស៊ីនចេញទៅហេហេហេហេហើយសំរាប់កាប៉ាល់ដែលអត់មានម៉ាស៊ីននឹងគឺវាបាននៅនឹងហាសបាទហេហេហេហេហើយដល់ពេលនឹងពួកគេនឹងបានទៅកោះឧញ្ញាតីនឹងគឺវាមិនបានអោយយើងនឹងបានចេញនោះទេហើយសំរាប់អីវ៉ាន់របស់យើងនឹងគឺនៅលើនឹងទាំងអស់ហើយយើងមានអ្វីទៀតមានតែខោមួយហើយនឹងអាវមួយតែប៉ុននោះទេបាទហើយសំរាប់ក្រមារនឹងវានៅជាប់នឹងចង្កេះរបស់យើងនឹងហាសហេហេហេវាមានចេញទៅណាសំរាប់ការប៉ាល់នឹងវាអត់មានម៉ាស៊ីនចឹងមានអ្វីដែលត្រូវនិយាយទៀតបាទហើយនៅពេលដែលវាបានចេញទៅចោលយើងនឹងគឺយើងនឹងគ្មានអ្វីបាននោះទេគឺមានតែខ្លួនរបស់យើងនឹងទទេនឹងជាប់នឹងខ្លួនរបស់យើងនឹងបាទ៕

ក៖

បាទហើយសំរាប់ពួកគឺគេបានយកអីវ៉ានរបស់យើងទៅទាំងអស់ហើយមែនដែលលោកតា???

ខ៖

បាទគឺពួកវាបានយកអីវ៉ាន់របស់យើងនឹងទៅទាំងអស់នឹងហាសបាទគឺវាយកទៅជាមួយនឹ

ងកាប៉ាល់នឹងហាសហើយសំរាប់យើងនឹងគឺយើងអស់មានអ្វីទាំងអស់នឹងបាទហើយនិយាយទៅគឺពួកវានឹងគឺបានបោកយើងនឹងទាំងរស់តែម្តងហាសបាទខ្ញុំប្រាប់ក្មួយឯងទៅបាទហើយនៅពេលដែលយើងបានទៅដល់នឹងហើយចឹងគឺទៅដល់ព្រៃកក្តាមហាសហើយសំរាប់ក្មួយឯងមានបានស្គាល់ព្រៃកក្តាមដែលរឺទេបាទហើយនៅពេលដែលយើងបានទៅដល់ព្រៃកក្តាមនឹងសំរាប់ឡានរបស់គេនឹងហាសហើយឡានរបស់គេនឹងគឺមានប្រហែលជា ១០០ឡានហើយសំរាប់ឡាននឹងវាទៅដល់វត្តឯនោះបាទវត្តអីសាននៅវត្តលោកហាសបាទហើយសំរាប់ឡាននឹងវានៅឆ្ងាយពីគ្នា ៥០ ម៉ែត្រមួយ ៥០ ម៉ែត្រមួយ

បាទហើយមើលទៅគឺវាបានបងតរគ្នាចឹងទៅហើយសំរាប់គេគេបានដាកឡានទី១នឹងសំរាប់ឡាន១០នឹងហាសហើយសំរាប់ឡានទី១នឹងគឺគេបានាទៅចុះនៅមោងឬស្សីនោះបាទនឹងសំរាប់ឡានទី១នឹងហាសបាទ១០នឹងគឺគេបានបែលមុខនឹងមកខេត្តបាត់ដំបងហើយសំរាប់ឡានទី២នឹងដែលមានឡាន១០នឹងគឺគេបានចុះមកដល់ខេត្តបាត់ដំបងហើយសំរាប់ឡានទី៣ដែលមាន១០ឡាននឹងគឺគេបានចុះនៅខេត្តពោធិ៍សាត់ហើយសំរាប់១០ឡានទៀតនឹងគឺគេបានចុះនៅស្ពឺចេះទេគេហៅថាខេត្តកំពុងឆ្នាំងហើយនិយាយទៅគឺគេបានដាក់បញ្ចុះអោយនៅគ្រាប់ទីកន្លែងតែម្តងហាសបាទហើយនៅពេលដែលយើងបានចុះទៅភូមិនឹងទៅដល់គឺគេបានចែកអោយយើងនឹងមួយអំរែកហើយបាទហើយនៅក្នុងមួយនឹងគឺគេត្រូវដាក់ប្រជាជននឹងប៉ុន្មាននាក់ឧទាហរណ៍ថាក្នុងមួយភូមិនឹងគឺគេបានដាក់ប្រជាជននឹងចំនួន ៣០០ នាក់បាទហើយសំរាប់មួយភូមិ ៣០០ នាក់សំរាប់មួយភូមិ ៣០០ នាក់ សំរាប់មួយភូមិ ៣០០ នាក់

បាទហើយគេបានវាយដាក់គ្រាប់កន្លែងចឹងទៅហាសបាទនឹងហើយហើយនៅពេលដែលគេបានសរុបទៅមនុស្សដែលបានស្លាប់នឹងក្នុងមួយភូមិនឹងមានប្រជាជន ៣០០នាក់ មួយភូមិនឹងមានប្រជាជន

៣០០នាក់ហើយដល់ពេលនឹងក្នុងមួយភូមិនឹងនៅសល់តែប្រជាជនតែ ៣០ នាក់អីចឹងហើយមានពេលនៅសល់តែ១០នាក់ផងចឹងហាសបាទនិយាយទៅអស់រលីងចឹងទៅហើយដល់ពេលអស់រលីងចឹងទៅគឺវាបានជាប់នឹងប្រវត្តមួយទៀតហើយខ្ញុំនិយាយអោយស្តាប់មួយប្រវត្តិមួយទៀតបាទនឹងសំរាប់ប្រវត្តខាងស្វាយរៀងវិញម្តងហាសបាទសំរាប់ជំនាន់នឹងគឺគេបានយកខាងពួកស្វាយរៀងទៅចឹងហាសបាទហើយសំរាប់ពយកស្វាយមុននឹងគេអោយទៅចឹងគឺគេបានអោយក្រមារមួយនឹងសំរាប់ក្រមារសរហើយនឹងពណ៌ខៀវមួយហាសបាទហើយដល់ពេលនឹងអោយតែមានអ្នកដែលមានឈ្មោះមកពីខាងស្វាយរៀងនឹងដឹងតែគេបានអោយក្រមារហើយបាទហើយសំរាប់ក្មេងក៏គេហើយនឹងសំរាប់មនុស្សចាស់ក៏គេបានអោយដែលបាទនឹងសំរាប់ខាងស្វាយរៀងនឹងគេដោយលែកចឹងទៅបានដល់ពេលខ្ញុំបានរស់នៅនឹងបាន៥រឺក៏១០ថ្ងៃចឹងទៅសំរាប់មិត្តយើងទាំងអស់គ្នាត្រូវការប្រជុំគឺថាដើម្បីនេះនឹងហាសគឺដើម្បីអោយយើងនឹងទៅច្រូកស្រូវនឹងហាសពីព្រោះអីនឹងសំរាប់ខេត្តមួយនឹងគឺសំបូរដោយស្រូវខ្លាំងណាស់បាទហើយនឹងសំរាប់នៅខាងចុងទន្លេរសាបរបស់យើងនឹងហាសបាទនិយាយទៅគឺសំបូរខ្លាំងណាស់ហើយនៅពេលនឹងគឺយើងបានដាក់កូនហើយនឹងបានដាក់ថៅអីអីទាំងអស់នឹងបានទៅដើម្បីអោយយើងបានធ្វើជាជំរុំដើម្បីច្រូកអីរួចច្រូកអី

រួចចាំយើងទាំងអស់គ្នានឹងឡើងមកវិញចឹងទៅនឹងហើយសំរាប់យើងនឹងដាក់កាំបិតហើយ
នឹងដាក់ពូថៅទៅតាមខ្លួនតែម្តងនិយាយទៅគឺគ្រាប់គ្នាធ្វើដូចគ្នាទាំងអស់តែត្រូវតែចឹងតែម្ត
ងហាសបាទហើយនៅពេលដែលយើងទៅនឹងគឺគេបានប្រេរួចជាស្រេចហើយនឹងសំរាប់គំ
និតរបស់ហាសបាទគឺគេបានប្រេក្នុយចេះគឺពួកពោលពតនឹងគឺគេបានប្រេសំរាប់គេរស់នៅ
ទីកន្លែងនឹងមានចំនួន១០នាក់ហើយសំរាប់ពួកពោលពតនឹងគឺគេបាននៅរង់ចាំនឹងទីន្លែងនឹ
ងដែលមានមនុស្សចំនួន១០នាក់ហើយនឹងកាំភ្លើងនឹង១០ដើមដែលបាទគឺគេបានទៅចាំ
នៅទីកន្លែងនឹងហើយនៅពេលដែលគេបានជំលាស់យើងពីនេះទៅមានចំនួន១០នាក់ទៀត
បាទនឹងសំរាប់ពួកពោលពតហាសបាទហើយសំរាប់១០នាក់ទៀតក្នុងមនុស្សម្នាក់នឹងគឺគេ
បានអោយកាន់កាំបិតមួយមនុស្សម្នាក់នឹងគឺគេបានអោយកាន់កាំបិតមួយមនុស្សម្នាក់នឹងគឺ
គេបានអោយកាន់កាំបិតមួយហើយពួកវាកាងកាងនឹងហាសហើយសំរាប់១០នាក់នឹងខ្លះមា
នកាំបិតនឹងហើយពួកគេនឹងបានដាក់កំបិតនឹងចង្កេះរួចជាស្រេចហើយនឹងគឺគេបានលាក់
ការហាសដល់ពេលនឹងសំរាប់រទេះហើយនឹងប្រដាប់ប្រដាល់ទាំងអស់នឹងគឺគេបានហៅពេ
លនឹងថាចុងហើយពេលនឹងពួកវាបានព័ទ្ធជុំវិញព្រៃចឹងទៅហាសដល់ពេលដែលចុងហើយ
ចឹងក្នុយអើយនិយាយទៅគឺពួកវាធ្វើតែ១ម៉ោងនោះទេគឺស្លាប់ទាំងអស់តែម្តងបាទគ្រាន់តែ
លឺស្វូរផើសហើយនឹងមានក្រចៃនឹងលឺស្វូរនឹងគឺពួកវានឹងនាំគេកាប់សំលាប់តែម្តងមានអ្នក
ខ្លះនឹងបានកាប់ពីខាងក្រោយហើយនឹងកាប់ពីមុខហើយពួកវាគិតតែដើលកាប់កាប់ហើយពួ
កវាកាប់នឹងគឺដូចជាកាប់ត្រីចឹងហាសបាទហើយមានអ្នកខ្លះនឹងគឺបានដាច់ក្បាលហើយសំ
រាប់អ្នកខ្លះទៀតនឹងគឺបានដាច់កន្ទុយហើយអ្នកខ្លះនឹងគឺបានដាច់កដៃហើយសំរាប់អ្នកខ្លះនឹ
ងគឺបានដាច់ជើងចឹងទៅហាសបាទហើយសំរាប់អ្នកខ្លះទៀតនឹងគឺគេរត់មិនរួចហើយនឹងសំ
រាប់អ្នកខ្លះទៀតនឹងក៏បានរត់រួចចឹងទៅហើយនៅប្រសិនជារត់រួចនឹងគឺនៅក្នុងព្រៃនឹងគឺពួក
វាបានចេញមកបាញ់ទៅចឹងទៅហើយសំរាប់យើងរត់ទៅណាវិញពីព្រោះអីនឹងនៅខាងក្រៅ
នឹងគឺជាវាល់ស្រែហើយសំរាប់នៅកន្លែងនឹងសំរាប់មួយវ៉ាល់នឹងមើលដាច់កន្ទុយភ្នែកហាស
បាទហើយពួកវាបានប្រលេងចោលដូចជាសត្វគោចឹងបាទហើយសំរាប់ក្នុយឯងមានដៃទ
ទេហើយសំរាប់ខ្ញុំមានកាំបិតនេះហើយទៅឈ្នះខ្ញុំដែលហាសក៏ប៉ុនតែទោះវាចេះយ៉ាងមិចក៏
នៅតែមិនឈ្នះដែលពីព្រោះអីគេគ្រាប់គ្នាមានសុទ្ធតែកាំបិតចឹងទៅឈ្នះគេមិននឹងបានហើ
យនៅពេលដែលវាទៅជាស្លន់ស្លោលងាប់ទាំងអស់តែម្តងហាសបាទហើយសរុបទាំងអស់
ទៅមនុស្ស ៣០០
នាក់គឺតែមួយភ្លេចនឹងហាសបាទហើយនឹងគឺសំរាប់មួយកន្លែងហើយសំរាប់យើងយើងមាន
បានដឹងណាគឺខ្ញុំបានទៅដល់ណាចឹងទៅនឹងសំរាប់ខ្ញុំគឺខ្ញុំឧទាហរណ៏ទេណាបាទគឺទៅដល់
រហូតស្រុកបាំរាំងឯងនោះទេបាទដល់តែខ្ញុំបានច្រូតស្រូវទៅដល់កន្លែងនឹងចឹងហាសបាទពី
ជំនាន់នឹងគឺសំបូរចាយណាស់បាទពីជំនាន់នឹងហាសបាទហើយសំរាប់យើងយើងមានបាន
ដឹងអ្វីពីព្រោះអីនឹងមិនបានដឹងថាគេបានយកយើងនឹងទៅសំលាប់ចោលចឹងហាសគឺមិនបា
នដឹងនោះទេបាទរួចហើយមកដល់អាពេលខាងក្រោយទៀតនេះគឺយើងមិនបានដល់នឹង
នោះទេបាទគ្រាន់តែយប់យប់នឹងគឺព្រលឹបនឹងគឺពួកវាបានចាប់យើងហើយវាបានវៃយើងនឹ
ងទំលាក់ចោលចូលទៅក្នុងអណ្តូលហាសបាទហើយសំរាប់យើងយើងរត់អ្វីរួចពីព្រោះអីនឹង

យើងគ្មានអ្វីនឹងតទាល់នឹងវាផងនឹងគឺយើងរត់គ្មានរួចនោះទេនឹងហើយបានជាខ្ញុំនឹងបានដឹងហាសបាទហើយសំរាប់អ្នកខ្លះនឹងក៏គេបានស្លាប់ទៅហាសនៅពេលយប់នឹងហាសហើយសំរាប់អ្នកខ្លះនឹងក៏មិនទាន់បានស្លាប់ចឹងទៅនិយាយទៅនៅប្រឡាយអណ្តូលដែលនៅខាងត្បូងឯងនោះនឹងដែលខ្ញុំនឹងបានឡើងដើមត្នោតនឹងហាសហើយខ្ញុំនឹងបានក្រឡេកឃើញសុទ្ធតែឈាមហើយនឹងប្រឡាក់ពេញដើមត្នោតនឹងប្រទិសប្រទាក់ពេញនឹងហើយសំរាប់ខ្ញុំគ្រាន់តែខ្ញុំនឹងបានឃើញចឹងទៅគឺខ្ញុំគ្រុនតែម្តងហើយសំរាប់ខ្ញុំដល់ឡេឡាក់ឡេឡាក់នឹងដើលទៅណាបាទហើយសំរាប់អ្នកខ្លះនឹងក៏គេបាននៅមានជីវិតចឹងទៅហើយសំរាប់អ្នកខ្លះទៀតនឹងគឺគេបានដាច់ដៃហើយនឹងដាច់ជើងបានស្លាប់ចឹងទៅបាទនិយាយទៅគឺវាវេទនាណាស់ប្រសិនជាខ្ញុំនិយាយពីប្រវត្តិរបស់ខ្ញុំនឹងបាទ៕

កៈ
បាទហើយចឹងអរគុណាច្រើនលោកតាសំរាប់ការផ្តល់យោលបល់សំរាប់ថ្ងៃនឹងចឹងខ្ញុំចង់សួរសំណួរលោកតាមួយទៀតថាតើលោកតាមានបានដឹងទេថានៅក្នុងជំនាន់ណាទេដែលគេបានមកជួយរំដោះប្រជាជនខ្មែររបស់យើងហាសលោកតាមានបានដឹងដែលរឺទេនៅក្នុងឆ្នាំណាលោកតានៅចាំដែលរឺទេលោកតា???

ខៈ
បាទសំរាប់ខ្ញុំដូចជានៅក្នុងជំនាន់នឹងដូចជាភ្លេចឆ្នាំដែលហាសបាទសំរាប់កាល់នឹងខ្ញុំដូចជាភ្លេចឆ្នាំហើយបាទនិយាយទៅគឺខ្ញុំបានចាំនឹងគឺ ៣ ឆ្នាំ ៨ ខែ ហើយនឹង ២០ថ្ងៃ
ហាសបាទប្រសិនជាយើងរាប់មកវិញមកដល់ល្ងូវនឹងដែលគេបានមកជួយរំដោះយើងនឹងដែលយើងបានចេញពី ៣ ឆ្នាំ ៨ ខែ ហើយនឹង
២០ថ្ងៃគឺយើងរាប់ពីនឹងមកវិញមកគឺយើងនឹងដឹងហើយបាទមកដល់ទាល់សព្វថ្ងៃនឹងបាទគឺនៅក្នុងឆ្នាំ ១៩៧៩
នឹងហើយបាទនឹងប្រសិនជាយើងរាប់ពីនឹងមកវិញចឹងគឺយើងបានដឹងហើយបាទហើយយើងគិតលេខពីនឹងហើយនឹងឆ្នាំពីនឹងមកគឺយើងដឹងហើយបាទបាទសំរាប់ ៣ ឆ្នាំ ៨ ខែ
ហើយនឹង
២០ថ្ងៃនឹងហាសគឺយើងនឹងដឹងហើយបាទហើយប្រសិនជាយើងនឹងរាប់មកដល់សព្វថ្ងៃនឹងគឺយើងនឹងបានដឹងហើយបាទ៕

កៈ
បាទហើយចឹងនៅពេលដែលគេបានជួយរំដោះលោកតាពីជំនាន់រដ្ឋប្រហារក៏ដូចជាជានៅក្នុងជំនាន់ពោលពតនឹងហាសហើយនៅពេលដែលគេបានជួយរំដោះលោកតាហើយចឹងថាតើលោកតារត់ទៅទីកន្លែងណាដែលទៅលោកតានិយាយទៅលោកតាតរត់ទៅស្រុកណាហើយនឹងខេត្តណាដែលទៅលោកតា???

ខៈ
បាទនៅពេលដែលគេបានជួយរំដោះខ្ញុំនឹងនៅក្នុងជំនាន់ពោលពតនឹងគឺថាពីដំបូងនឹងគឺខ្ញុំមិ

នទាន់បានមកដល់ទីន្លែងនឹងនោះទេបាទសំរាប់ខ្ញុំនឹងគឺខ្ញុំបានរស់នៅផ្សារខេត្តពោធិ៍សាត់ហាសបាទហើយសំរាប់នៅក្នុងជំនាន់នឹងគឺបងរបស់ខ្ញុំនឹងគាត់គឺជាបងជីដូចមួយរបស់ខ្ញុំនឹងហាសបាទហើយសំរាប់បងរបស់ខ្ញុំនឹងគឺគាត់បានធ្វើការងារជាកម្មាខេត្តនឹងកម្មារក្រុងសំរាប់ខេត្តពោធិ៍សាត់ហាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងបានរស់នៅនឹងបានចំនួន១ខែហើយនៅពេលដែលខ្ញុំនឹងបាននិយាយពីប្រវត្តិរបស់ខ្ញុំនឹងហាសបាទហើយសំរាប់កាល់នឹងគឺខ្ញុំនឹងបានររស់នៅទីកន្លែងនឹងបាន១ខែចឹងទៅគឺថាគេបានជំលាស់ខ្ញុំនឹងគឺទៅដល់វត្តសុខសាន្តហាសហើយសំរាប់ក្មួយឯងដែលបានលឺគេនិយាយពីកន្លែងនឹងដែលរឺទេហើយសំរាប់វត្តសុខសាន្តនឹងគឺនៅស្រុកសំឡូរហាសបាទហើយសំរាប់វត្តសុខសាន្តនឹងគឺវានៅក្នុងស្រុកសំឡូតហាសបាទហើយនៅពេលដែលគេបានជំលាស់យើងទៅហើយនឹងសំរាប់ប្រពន្ធកូនចៅរបស់ខ្ញុំនឹងគឺគេបានជំលាស់ពួកគេនឹងឡើងទៅលើភ្នំនោះគឺពួកគេបានឡើងទៅភ្នំបាចាបនោះបាទហើយសំរាប់យើងនឹងវាឆ្ងាយពីវត្តសុខសាន្តពីនឹងចំងាយ១០គីឡូរទៀតហាសបាទហើយសំរាប់មកដល់ខ្ញុំនឹងគឺគេបានអោយខ្ញុំនឹងបានចុះមកវិញគឺដើម្បីមកប្រមូលស្រូវហើយនឹងអង្ករនឹងមកផ្សារពោធិ៍សាត់នឹងគឺសំរាប់ប្រពន្ធហើយនឹងកូនរបស់ខ្ញុំនឹងហាសបាទហើយនិយាយទៅពីដំបូងនឹងគឺខ្ញុំបានផ្ញើរអោយប្រពន្ធហើយនឹងកូនរបស់ខ្ញុំនឹងបានចំនួនម១កេះនឹងគឺសំរាប់អង្ករហាសហើយនឹងមានត្រីងៀតគឺជាត្រីនឹងហាសហើយយើងផ្ញើរទៅចឹងហាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំមានមិត្តភក្តិម្នាក់ដែលគេមានរទេះគោចឹងហាសបាទហើយគេបានដឹងទៅដោយរទេះហើយសំរាប់យើងនឹងក៏បានផ្ញើរអីវ៉ាន់នឹងទៅតាមគេចឹងហាសបាទហើយនៅពេលដែលខ្ញុំនឹងបានផ្ញើរទៅពេលក្រោយទៀតគឺគេបាននិយាយថាមិនបាច់ផ្ញើរទៅទៀតនោះទេបាទពីព្រោះអីនឹងគឺថាគេបានអោយអ្នកទាំងអស់នឹងយកទៅវៃចោលអស់ហើយនឹងហើយសំរាប់ប្រពន្ធហើយនឹងកូននឹងគឺមិនបាច់ផ្ញើរទៀតទេគឺចប់អស់ហើយពីព្រោះអីនឹងគឺគេបានយកទៅវៃចោលអស់ហើយចឹងហាសបាទដែលពួកគាត់នឹងគឺខាងវត្តចាបនឹងហាសបាទហើយដល់ពេលចឹងទៅសំរាប់ខ្ញុំនឹងគឺខ្ញុំក៏មាគំណិតថាសំរាប់ខ្ញុំគឺខ្ញុំមិនដឹងជារកអោយអ្នកណាទៀតនោះទេហើយពេលនឹងក៏ខ្ញុំបានរកចូលទៅស្រុកយួននឹងតែម្តងទៅហាសបាទហើយនៅពេលដែលខ្ញុំនឹងចង់រត់ចូលស្រុកយួននឹងគឺខ្ញុំនឹងត្រូវនឹងស្លាប់ម្តងទៀតកំអីនឹងខ្ញុំនឹងស្លាប់ម្តងទៀតហើយហើយម៉ារនៅក្នុងជំនាន់នឹងហាសហើយនិយាយទៅគឺវេទនាណាស់បាទហើយនៅពេលដែលខ្ញុំនឹងបានរត់ចូលស្រុកយួននឹងគឺខ្ញុំគ្មានអ្វីនឹងបានផឹកនោះទេគឺយើងទាំងអស់គ្នានឹងផឹកតែទឹកនោមនោះទេបាទហើយនៅពេលដែលយើតចង់រត់ទៅស្រុកយួននឹងហើយសំរាប់ស្រុកយួននឹងគឺវាមិនជាសូវជាឆ្ងាយនោះទេបាទនិយាយទៅស្រុកយួននឹងនៅប្រហែលជានៅម៉្តុំយក្សនឹងហាសបាទនិយាយទៅគឺវាបិនបិននឹងហើយសំរាប់ការខាន់របស់វានឹងហើយដល់ពេលចឹងទៅដល់ពេលយប់នឹងគឺវាជនជាតិយួននឹងមានចំនួន២នាក់ហាសបាទពីព្រោះអីនឹងសំរាប់អ្នកដែលនៅស្រុកខេត្តពោធិ៍សាត់នឹងមានចំនួន២នាក់នឹងគឺគេបានស្គាល់ផ្លូវនឹងក៏បាននាំគ្នាដើលដើលរហូតហើយនៅពេលដែលយើងបានដើរនឹងគឺយើងបានដើរដល់មុខសញ្ញារបស់ជនជាតិយួននឹងថៃនឹងគឺមិនដល់១០០ម៉ែត្រពីគ្នានោះទេបាទហើយនៅពេលដែលយើងដល់នឹងគឺពួកវានឹងបានស្រែតែម្តងហាសបាទហើយនៅពេលដែលពួកវាបានស្រែហើយចឹងបងអើយអោយខ្ញុំនឹងសុំចូលទៅផងគឺ

ខ្ញុំបានស្រែទៅហាសបាទហើយឈ្លួមនឹងគឺគេបានពទ្ធ័ជុំវិញហើយដល់ពេលចឹងទៅពួកអាវក្រហមនឹងគឺពួកវានឹងបានដេញបាញ់ពីខាងក្រោយយើងនឹងតែម្តងហាសហើយមានម្នាក់នឹងវាបានជិតសេះសរនឹងដេញបាញ់បាញ់បែកផ្សែងដល់ពេលដែលគេបានបាញ់បែកផ្សែងហើយចឹងហើយសំរាប់យួននឹងគឺគេបានឃើញគេនឹងបានបាញ់ខ្ញុំនឹងគឺខ្ញុំបានរត់ចូលប្រឡាយហើយគេបាញ់ខ្ញុំនឹងមិនបានត្រូវហាសបាទហើយដល់ពេលនឹងគេនឹងក៏បានបង្វែលកាណុងការដេវាររបស់គេនឹងហាសពួកគេបានបង្វែលហើយដំរងទៅបាញ់ពួកពោលពតវិញចឹងហាសបាទបានអាសេះនឹងរត់ចេញទៅវិញចឹងទៅកុំអីនឹងគឺខ្ញុំនឹងបានស្លាប់ពេលនឹងហើយបាទហើយពួកយួននឹងវាបានឈរនៅនឹងទៀតហើយប្រសិនជាមិនជឿរទេទៅសួរពូរត្ន័មើលដែលនៅក្នុងជំនាន់ពោលពតហាសបាទពីព្រោះអីនឹងយើងធ្វើជាមេកងមេអីនឹងពីព្រោះអីនឹងគឺខ្ញុំបានរ៉ែកដីរ៉ែកអីនឹងគឺពេលនឹងដើលពាន់ជើងអីនឹងគឺមិនដែលបានធ្វើការងារអ្វីនោះទេបាទហើយយើងជីកជីកហើយយើងបានប្រាប់គេនឹងតាមត្រង់ចឹងទៅហើយនៅពេលដែលយើងប្រាប់គេតាមត្រង់នឹងគឺគេមិនបានធ្វើអ្វីយើងនឹងនោះទេបាទដល់ពេលចឹងទៅសំរាប់នៅកន្លែងគត់នឹងគឺវាត្រូវចាប់ដាក់គត់ដែលនៅប្រសាទព្រៃគត់នឹងហាសបាទដល់ពេលហើយចឹងទៅនៅពេលដែលយើងបានដើលចេញពីគត់ហើយចឹងទៅគឺគេបានអោយយើងនឹងធ្វើការងារចឹងទៅហាសបាទដល់ពេលហើយចឹងសំរាប់ប្រពន្ធរបស់ខ្ញុំនឹងហាសដែលគាត់រស់នៅក្នុងព្រៃនឹងដែលគេនឹងត្រូវយកគាត់នឹងវៃចោលចឹងហាសដល់ពេលគេយកវៃចោលចឹងមានគេម្នាក់នឹងគេបានស្គាល់ខ្ញុំនឹងគឺគេបាននិយាយថាតាធូតាធូតាធូយាយរស់នឹងគឺគាត់មិនទាល់បានស្លាប់នោះទេហើយសំរាប់យាយរស់នឹងគឺយើងបានឃើញគាត់នឹងបានដើលតាមជាមួយនឹងម្តាយរបស់គាត់ហាសបាទហើយគាត់នឹងបានតាមរកតាធូឯងនឹងហាសបាទរួចហើយមិចតាធូឯងមិនជួយមើលផងហាសបាទហើយគ្រាន់តែពេលដែលខ្ញុំបានលឺចឹងហើយគឺខ្ញុំនឹងក៏បានទៅគឺខ្ញុំនឹងទៅជួបគ្នាចឹងហាសបាទហើយនៅពេលដែលយើងបានជួបគ្នានឹងគឺជួបគ្នានៅផ្សារពោធិ៍សាត់នឹងហាសហើយយើងទាំងអស់គ្នានឹងបានរស់នៅផ្សារពោធិ៍សាត់នឹងបាន៩រឺក៏១០ថ្ងៃអីចឹងហើយសំរាប់ខ្ញុំនឹងក៏បាននាំប្រពន្ធហើយនឹងម្តាយរបស់ខ្ញុំនឹងក៏បានមកផ្ទះរបស់ខ្ញុំវិញចឹងទៅបាទហើយយើងនាំមកនៅកោះដាច់នឹងរហូតមកបាទហើយសំរាប់ម្តាយរបស់ខ្ញុំនឹងគឺគាត់គឺជាម្តាយក្មេករបស់ខ្ញុំនឹងសូម្បីតែបារីនឹងក៏បានមូលអោយយើងនឹងជក់ដែលហើយសំរាប់ខ្ញុំកាល់ពីដើមនឹងគឺគាត់សូម្បីតែបារីដែលខ្ញុំបាននិយាយប្រាប់ក្មួយឯងនឹងសំរាប់ឪពុកនឹងគឺគាត់ស្រឡាញ់កូនពេកចឹងហាសបាទតាំងពីខ្ញុំនឹងមានអាយុ១២ឆ្នាំមកម្លេះហើយសំរាប់បារីនឹងគឺគាត់មិនបានអោយកូននឹងមូលនោះទេគឺគាត់សុខចិត្តមូលបារីនឹងអោយកូននឹងបានជក់រួចហើយសំរាប់ប្រអបប្រាក់របស់យើងហាសគឺជាប្រាក់សហាសគឺគាត់បានទិញប្រអប់ប្រាក់នឹងយកមកដាក់បារីនឹងទុក្ខអោយយើងនឹងជក់ទៀតរួចហើយក្នុងការដើរនឹងគឺគាត់មិនបានអោយកូននឹងដើរទៀតគឺឪពុករបស់ខ្ញុំនឹងមិនបានអោយយើងនឹងដើរនោះទេនៅពេលដែលគាត់បានធ្វើដងរ៉ែកហើយចឹងគឺគាត់ដាក់យើងនឹងទៅក្នុងអន់រ៉ែកហើយគាត់បានរ៉ែកយើងចឹងទៅហើយនៅពេលដែលគាត់រ៉ែកនឹងគឺមានអាថោងមួយហើយនឹងខ្ញុំមួយដែលនឹងហើយគឺគាត់បានរ៉ែកយើងទាំង២នាក់ចឹងហាសហើយសំរាប់ផ្ទះរបស់គាត់ចំងាយពីនឹងមានចំងាយ៩គីឡូរហាសបាទហើយគាត់រ៉ែក

កូនរបស់គាត់នឹងវាពិបាក់ណាស់តែសំរាប់ខ្ញុំនឹងគឺខ្ញុំនិយាយពីបាយទឹកនឹងហាសបាទហោ ហោហោហោអស់ពោះអត់ម្ដាយហើយពីព្រោះអីនឹងតាំងពីខ្ញុំបានកើតពីពោះម្ដាយរបស់ខ្ញុំមក ក៏ដូចឪពុកហើយនឹងម្ដាយរបស់ខ្ញុំហាសទើបតែកូនមកជំនាន់ក្រោយនឹងមកវាទៅជាឆ្គួតអ ស់វិញដល់ពេលសំរាប់អាមួយនឹងគឺខ្ញុំនឹងមិនដឹងជានិយាយយ៉ាងមិចនោះទេបាទពីមុខនឹង គឺវានឹងដូចសំពុតនឹងនៅក្នុងផ្ទុតចឹងហាសហើយនិយាយទៅគឺវាល្អណាស់ហើយដល់ពេល ដែលវាមានប្រពន្ធកូនហើយចឹងទៅវាមានតាំងពីស្រីញ្ញីហើយនឹងមានតាំងកាវ៉ាអូខេហើយ សំរាប់មកដល់រាល់ថ្ងៃនឹងហាសបាទកង់៣នឹងគឺយើងបានអោយម៉ូតូនឹង១ហើយយើងនឹង បានទិញនឹងវាថ្មីតែម្ដងហាសហើយយើងទិញនឹងគឺយើងទិញអស់ ២០០០$
ជាងហើយវានឹងយកទៅបានតែ៤ថ្ងៃរឺក៏៥ថ្ងៃនឹងវាបានយកទៅលក់អស់ទៀតហើយនិយា យទៅគឺខ្ចិចគឺមិនសល់នោះទេរួចហើយនៅពេលដែលវានឹងទៅរត់កង់៣នឹងក្នុងមួយថ្ងៃនឹង បានលុយ ៣០០០០៛រឺក៏ ៤០០០០៛រឺក៏ ៥០០០០០៛
នឹងនិយាយទៅគឺអស់តែម្ដងហើយនៅពេលដែលវាផឹកហើយចឹងគឺវានឹងទៅចូលទៅកាវ៉ាអូ ខេហើយបាទហើយនិយាយទៅគឺវានឹងមានកូនច្រើនណាស់ហើយកូនរបស់វានឹងដូចជាកូ នចាបចឹងហាសបាទហើយនៅពេលដែលខ្ញុំនឹងបានឃើញចៅរបស់ខ្ញុំចឹងទៅនៅពេលដែ លខ្ញុំបានឃើញគឺខ្ញុំតែងតែហុចលុយនឹងអោយចៅរបស់ខ្ញុំហើយហើយសំរាប់ខ្ញុំនឹងគឺខ្ញុំប្រា ប់ក្មួយឯងនឹងតាមត្រង់ហាសសំរាប់ខ្ញុំគឺខ្ញុំដើរទៅយកត្រយ៉ូងចេកពីគេហើយនឹងទិញស្ពៃ ហើយនឹងត្រលាចរបស់គេមកចឹងទៅហាសហើយបន្លែទាំងអស់នឹងនៅពេលដែលយើងបា នទិញហើយចឹងគឺក្នុង១គីឡូនឹងគឺយើងចំនេញបានតែ ១០០០៛
នោះទេបាទហើយមានពេលខ្លះនឹងគឺបានតែ ៥០០៛
នោះទេក្នុងមួយព្រឹកនឹងគឺយើងយកទៅលក់២នាក់តាហើយយាយនឹងហើយនិយាយទៅស រុបទៅក្នុងមួយថ្ងៃនឹងគឺ២នាក់តាហើយយាយនឹងបានក្នុងមួយថ្ងៃនឹង ២០០០០៛
នៅក្នុងមួយព្រឹកនឹងហាសបាទហើយមានខ្លះទៀតនឹងគឺយើងបាន ១០០០០៛
ចឹងទៅនិយាយទៅគឺ២នាក់តាហើយយាយនឹងគឺបានតែបិននឹងហើយមានបានអ្វីនោះទេ ហើយដល់ពេលកូននឹងវាមកធ្វើចឹងទៅគឺសំរាប់ខ្ញុំនឹងគឺខ្ញុំវេទនាខ្លួនណាស់ហើយសំរាប់មួ យទៀតនឹងផ្ទះរបស់វានឹងថ្មីចេសហើយនៅពេលដែលធ្វើនឹងអស់ ១៥០០០$
បាទដល់ពេលហើយយើងគិតគូរការងារហើយដល់យកវាដើរបេះស្វាយអោយគេហើយនឹង ដើរស៊ីឈ្នួលអោយបាន ១០០០០០៛
អីនឹងគឺវាយកលុយទាំងអស់នឹងយកទៅជល់មាន់ទៀតហើយបាទហើយនិយាយទៅសំរាប់ ខ្ញុំនឹងវាអីក៏ពិបាក់ម្លេះបាទ៕

កៈ
បាទហើយចឹងអរគុណាច្រើនលោកតាហើយចឹងខ្ញុំចង់សួរលោកតាតែបន្តិចទៀតទេថាតើ នៅពេលដែលលោកតាបានដើរមកពីខេត្តពោធិ៍សាត់ហើយមកដល់កោះដាច់នេះវិញថាតើ លោកតាដើរមករឺក៏ជិះអ្វីមកដែលទៅលោកតា???

ខ៖
បាទនៅពេលដែលខ្ញុំចេញពីពោធិសាត់នឹងគឺខ្ញុំបានជិះឡានមកចឹងហាសបាទហើយនៅពេលដែលយើងបានជិះឡាននឹងបានមកនឹងគឺគេបានយកកក្នុងម្នាក់នឹងមាសចំនួន ១ជីបាទគឺជា ១ជីមាស បាទបាទ៕

ក៖
បាទហើយចឹងនៅពេលដែលលោកតាបានជិះឡាននឹងហើយគឺគេបានយកមាសនឹងចំនួន ១ជីថាតើលោកតាជីមកកោះនឹងប្រើពេលអស់រយះពេលប៉ុន្មានថ្ងៃប៉ុន្មានខែដែលទៅលោកតា???

ខ៖
បាទនិយាយទៅពីខេត្តពោធិ៍សាត់នឹងគឺពេលព្រឹកហើយនឹងដល់ពេលល្ងាចនឹងគឺមកដល់ហើយបាទហើយនៅពេលដែលយើងបានមកដល់ហើយចឹងគឺយើងបានសំរាក់នៅគីឡូលេខ ៧ ហាសនៅគីឡូរលេខ ៧ ដែលមានពួកចាមហាសបាទនិយាយទៅនៅគីឡូរលេខ ៧ នឹងនៅគីឡូរលេខ ៨
ដល់ពេលព្រឹកឡើងចឹងទៅបានយើងនឹងបានជិះដរហើយសំរាប់កាល់នឹងគឺគ្មានដរនោះទេគឺមានតែទូតដែលគេបានចំលងមកចឹងទៅយកមកដាក់នៅកោះនឹងហាសបាទវាមិនមែនមានទូតហើយនឹងកាណូតមកដូចល្ងូរនឹងគឺគ្មាននោះទេបាទយកលុយ ១០០៛ ទៅថៅ៕

ក៖
បាទហើយចឹងចង់ខ្ញុំចង់សួរណ្ហូរលោកតាមួយទៀតនៅពេលដែលលោកតាបានមកដល់កោះនេះហើយចឹងថាតើសព្វថ្ងៃនេះលោកតាបានប្រកបមុខរបបអ្វីដែលទៅលោកតា???

ខ៖
បាទសំរាប់ខ្ញុំកាល់ដែលខ្ញុំនឹងបានចេញនឹងដំបូងមកគឺសំរាប់ខ្ញុំគឺខ្ញុំឡើងតែត្នោតដែលចឹងហាសបាទហើយនៅពេលដែលខ្ញុំបានឡើងដើមត្នោតនឹងក្នុងមួយថ្ងៃនឹងគឺខ្ញុំបាន១០គីឡូរដែលចឹងហាសបាទហើយមានពេលខ្លះនឹងគឺខ្ញុះបាន ៦គីឡូរ ៧គីឡូរ ៨គីឡូរ
ចឹងទៅហាសនឹងសំរាប់រាល់ថ្ងៃនឹងហាសបាទហើយនៅពេលដែលខ្ញុំនឹងបានឡើងដើមត្នោតនឹងដែលខ្ញុំនឹងមានវ័យនឹង ៣០ ឆ្នាំ រឺក៏អាយុ ២៥ ឆ្នាំ ហើយរហូតដល់ ៥០ឆ្នាំ
ដល់ហើយចឹងទៅសំរាប់មានអាយុ ៥០ ឆ្នាំ
គឺខ្ញុំនឹងបានចូលរដ្ឋហើយនៅពេលដែលខ្ញុំនឹងបានចូលវត្តហើយចឹងគឺខ្ញុំបានចូលអស់រយះពេលប្រហែល ១៧ ឆ្នាំ
ហើយនៅពេលដែលខ្ញុំនឹងបានចូលវត្តនឹងហើយខ្ញុំបានរៀនហើយសំរាប់វត្តរបស់គេនឹងគឺគេបានគោរពវិន័យរបស់គេណាស់បាទ៕

ក៖ បាទហើយចឹងលោកតានៅវត្តនឹងយូរមែនទែននៅរហូតដល់ ១៧ឆ្នាំ៕

ខ៖
បាទនិយាយទៅគឺអត់ទេយើងគ្រាន់តែយើងនឹងទៅវត្តទៅវ៉ាធ្វើបុណ្យធ្វើទានចឹងហាសគឺមិនមែនយើងទៅរស់នៅក្នុងវត្តនឹងទេបាទគឺយើងនឹងទៅទទួលសល់ហើយនឹងគេទាំងអស់គ្នានឹងគឺគេរាប់អានខ្ញុំនឹងហើយនឹងស្រឡាញ់ខ្ញុំចឹងហាសដូចថាមានកន្លែងណាមានការសូត្រធម៌សូត្រអីចឹងទៅហើយនឹងមានការមានបុណ្យអីចឹងទៅយើងនឹងទៅហើយបាទហើយប្រសិនជានិយាយពីធម៌អាហើយនឹងវិន័យវិញនឹងគឺគេគោរពបានល្អណាស់បាទ៕

ក៖
បាទហើយចឹងខ្ញុំចង់សួរលោកតាមួយថាតើបច្ចុប្បន្ននឹងទីកន្លែងបច្ចុប្បន្នរបស់លោកតានៅកន្លែងមានឈ្មោះអ្វីដែលទៅលោកតានៅភូមិស្រុកអ្វីហើយនឹងខេត្តអ្វីដែលទៅលោកតា???

ខ៖
បាទសំរាប់ទីលំនៅរបស់ខ្ញុំបច្ចុប្បន្ននឹងគឺនៅភូមិក្បាលកោះភូមិក្បាលកោះភូមិកោះដាច់ដែលហើយភូមិក្បាលកោះនឹងមានស្រុកមុខកំពូលខេត្តកណ្ដាលដែលបាទក៏ប៉ុនតែនឹងសព្វថ្ងៃនឹងគេបានប្ដូរឈ្មោះមកថាភូមិក្បាលកោះខណ្ឌជ្រោយចង្វារនៅភូមិភូមិកោះដាច់ខណ្ឌជ្រោយចង្វារហោហោហោហោតែប៉ុននឹងបាទ៕

ក៖
បាទហើយចឹងខ្ញុំចង់អោយលោកតាប្រាប់ខ្ញុំបានទេថាតើនៅពេលដែលលោកតាបានរស់នៅបច្ចុប្បន្ននេះប្រៀបធាបទៅនឹងជីវិតពោលពងនេះមានភាណសប្បាយយ៉ាងមិចដែលទៅលោកតាអាចប្រាប់ខ្ញុំបានដែលរឺទេលោកតា???

ខ៖ បាទប្រសិននិយាយទៅគឺថាសប្បាយដូចនៅឋានសួគ៌
ចឹងហាសហោហោហោហើយយើងចង់ទៅណាក៏បានហើយនឹងរកអ្វីនឹងក៏បានដែលចឹងហាសហោហោហោហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបានទៅធ្វើចំការអោយគេនឹងបានមួយម្ដងមួយម្ដងហើយសំរាប់ធ្វើចំការម្ដងនឹងយ៉ាងតូចនឹងអស់ ៤,៥០០,០០០
រៀលបាទហើយធ្វើដីនឹងគឺអស់៥រឺក៏៦ក្បាលហាសពីព្រោះអីនឹងគឺយើងបានប្រើកម្មករហើយប្រើជីអោយបានល្អចឹងហាសហើយនៅក្នុងមួយថ្ងៃនឹងគឺ៣នាក់រឺក៏៥នាក់រឺក៏៦នាក់រឺក៏៧នាក់រឺក៏១០នាក់អីចឹងទៅនិយាយទៅគឺដាំពោតហាសក៏ប៉ុនតែសំរាប់ចំនួនមួយនោះពោតនឹងនៅពេលដែលយើងធ្វើបានចឹងគឺគេចេះតែម៉ៅចឹងទៅហើយសំរាប់ការខ្លះនឹងក៏បាន ២,០០០,០០០៛ ហើយមានខ្លះនឹងបាន ៣,០០០,០០០៛ ហើយនឹងមានខ្លះនឹងក៏បាន ១,០០០,០០០៛ បាទហើយទាំងអស់នឹងគឺយើងចំនេញបានមួយសារនឹងបាន ១,០០០,០០០៛ រឺក៏
២,០០០,០០០៛ចឹងទៅបាទហើយនិយាយទៅគឺទាំងអស់ដែលចំនេញនឹងបានមកហើយចឹងគឺយើងបានកាត់ការចំណាយហើយចឹងហាសបាន ២,០០០,០០០៛
ដែលបាទហើយមកដល់លូវនឹងគឺយើងគ្មានកម្មករសំរាប់នឹងប្រើនោះទេបាទហើយណាមួយនឹងគឺសំរាប់វាកាន់តែចាស់ហើយនឹងកំលាំងនឹងគឺមិនសូវជាមានទៀតនោះទេបាទហើយ

លូវនឹងគឺខ្ញុំបានធ្វើដែលក៏ប៉ុនតែគឺខ្ញុំធ្វើបន្លែអីដែលចឹងហាសបាទគឺខ្ញុំដាំបន្លែស្ពៃក្រញ្ញៃបន្តិចចឹទៅហើយនឹងដាំបន្លែស្ពៃចង្កឹះបន្តិចចឹងទៅបាទហើយនឹងស្ពៃខ្មៅបន្តិចចឹងទៅនិយាយទៅគឺបន្លែបន្តិចចឹងទៅហើយនិយាយទៅដូចជាជីអីទាំងអស់នេះគ្រាន់តែខ្ញុំនឹងដើរបានមួយជុំផ្ទះរបស់ខ្ញុំនឹងហើយគ្រាន់តែដើរតែប៉ុននឹងគឺខ្ញុំនឹងបានលុយ
២០០០០រៀលដែលបាទហើយនិយាយទៅយើងមានតែ២នាក់យាយហើយនឹងតានឹងវាមានទៅពីបាក់អ្វីហេហេហេហេនិយាយទៅគឺវាស្រួលហើយប្រសិនជានិយាយទៅពីជំនាន់ពោលពតហើយនឹងមកដល់លូវនឹងគឺវាខុសគ្នាដូចមេឃហើយនឹងដីចឹងហាសបាទក៏ប៉ុនតែសំរាប់ជំនាន់នោះគឺជាជំនាន់ពោលពតនឹងមកដល់ជំនាន់មួយនេះហើយកាលនៅក្នុងជំនាន់របស់ខ្ញុំនឹងគឺខ្ញុំនឹងមានមុខរបបនឹងកាន់ជាប់នឹងនឹងខ្លួនចឹងហាសគឺខ្ញុំនឹងមានរបបនឹងច្រើនណាស់ហើយនិយាយទៅគឺខ្ញុំនឹងមិនអួតនោះទេបាទហើយសំរាប់របបនឹងគឺជារបបដែលខ្ញុំនឹងបានឡើងដើមត្នោតនឹងហាសបាទគឺខ្ញុំនឹងបានស៊ីបានឆ្អែតហើយនឹងស៊ីបានតាមចិត្តរបស់ខ្ញុំនឹងគឺខ្ញុំនឹងមិនដែលបានទៅស៊ីបបរស៊ីអីដែលមិនបានឆ្អែតដូចអ្នកផ្សេងអីនោះទេបាទហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងបានស៊ីសុទ្ធតែបាយជាមួយនឹងត្រីចឹងហាសហើយសំរាប់ត្រីដែលនៅក្នុងជំនាន់នោះវិញគឺវាធំធំណាស់បិនកំពូនជើងរបស់យើងហាសបាទហើយយើងគ្រាន់តែកាន់កាំបិតមួយហើយនឹងព្រួយមួយនឹងពេលដែលយើងបានមកវិញគឺយើងនឹងយូលគឺយូលនឹងមិនចង់រួចនោះទេបាទហើយសំបូរបំផុងជាងគេនឹងគឺជាខេត្តពោធិ៍សាត់នឹងហើយបាទនិយាយទៅគឺដៃទន្លេរសាបហាសបាទគឺវាច្រើនណាស់នឹងសំរាប់ត្រីហាសហើយសំរាប់រោងវាល់ស្រែវិញនឹងគ្រាន់តែរោងរបស់វានឹងគឺបិនបិននេះបាទគឺធំណាស់បាទនៅពេលដែលយើងគ្រាន់តែទៅឡើងអើតមើលនឹងគក៏បានកន្លះទ្រង់ដែលបាទហើយនិយាយរួមទៅមានដូចជា ត្រី អន្ទែន ហើយនឹងត្រីកំភ្លៀង ហើយនឹងត្រីតុស ហើយនឹងអន្លង
បាទនិយាយទៅគឺមានត្រីនឹងគ្រាប់មុខនឹងតែម្តងហាសបាទហើយមានឯងណាបាទគឺយើងបានស៊ីចុចនឹងបានឆ្អែតបាទហើយសំរាប់ក្រៅពីនឹងវិញមើលទៅគ្រាន់តែស្រូវនឹងអង្ករនឹងបានតែ៣កំប៉ុងហើយសំរាប់អង្ករ៣កំប៉ុងនឹងលាយជាមួយនឹងទឹកមួយខ្ទះបាទមួយខ្ទះត្នោតនឹងបាទហើយរស់គឺរស់ដោយសារទាំងអស់នឹងនោះទេហើយប្រសិនជារស់ជំនាន់នឹងហើយប្រសិនជាគ្មាននោះទេគឺស្លាប់អស់ហើយបាទហើយសំរាប់អ្នកដែលគេបាននៅរស់នៅមានជីវិតនឹងហាសគឺមាន៣មុខសញ្ញា អ្នកដែលរស់មានជីវិតទី១នឹងអ្នកដែលឡើងត្នោត
ហើយអ្នកដែលរស់មានជីវិតទី២នឹង អ្នកដែលដាំបន្លែ
ហើយនឹងអ្នកដែលរស់មានជីវិតទី៣នឹងគឺជាកិនស្រូវនឹងសំរាប់កងកិនស្រូវហើយអាស្រូវដែលក្បាលដែកដែលគេកិនស្រូវហាសហើយសំរាប់ក្មួយឯងនឹងដែលបានធ្លាប់ស្គាល់ដែលរឺទេ???

ក៖
បាទហើយសំរាប់ខ្ញុំគឺខ្ញុំស្គាលពីព្រោះអីនឹងគឺខ្ញុំធ្លាប់បានលឺចាស់ចាស់គាត់បាននិយាយបាទ ៕

ខ៖

បាទហើយដូចថានៅពេលដែលយើងបានកិនស្រូវនឹងគឺយើងមិនទៅយកទាំងបាវទាំងបាវហើយយើងបានកន្ទុតអីនឹងគឺយើងនឹងបានកញ្ចប់វានឹងបានមួយកញ្ចប់អីចឹងទៅហើយយើងយកទៅដុសហើយនឹងទៅអាំងអីចឹងទៅហើយអ្វីដែលឆ្ងាញ់បំផុងនឹងសំរាប់ក្មួយឯងមិនដែលបានហូបនោះទេនោះគឺជាគល់ចេករបស់យើងនឹងហាសបាទនិយាយទៅអាគល់របស់វាដែលមាននៅនឹងដីនឹងអាក្តើលរបស់វានឹងហាសបាទគឺយើងអានឹងមកប្រលាក់ផេះបន្តិចបន្តិចទៅហើយយើងវានឹងទៅអាំងចឹងទៅបាទនិយាយទៅឆ្ងាញ់ខ្លាំងណាស់បាទហើយសំរាប់មកដល់លូវនឹងយើងមានទាំងសាច់ជ្រូកខ្វៃហើយនឹងកាំងភ្លៅអីនឹងគឺយើងនឹងមិនទាំងចង់ស៊ីផងហាសបាទហេហេហេហេហេនិយាយទៅគឺមិនខ្វីទាំងចង់មើលផងលោកអើយហើយសំរាប់ខ្ញុំនឹងសព្វថ្ងៃនឹង២នាក់យាយហើយនឹងតានឹងទាំងចៅនឹងនៅពេលដែលទិញមកនឹងគឺចង់នឹងស៊ីផងហាសបាទហើយសំរាប់ដំណាបចេកនឹងគឺយើងនឹងហាលទុក្ខវាចោលចឹងទៅហើយប្រសិនជាក្មួយឯងឈរពីទៅមើលទៅដល់មាត់ទឹកនឹងមានចំនួន ២០០ ស្លួងហើយចាស់ទុក្ខចោលចឹងហាសហើយប្រសិនជាយើងនឹងលក់តែ ១៥០០៛ ផងនឹងក៏គេមិនចង់ទិញផងហាសបាទនឹងនៅក្នុង ១ស្និតហាស ១៥០០៛ បាទហើយ១៥០០៛រឺក៏១០០០៛នឹងក៏គេមិនចង់ទិញដែលបាទហើយសំរាប់ចេករបស់យើងនៅពេលដែលវាបានទុំចឹងទៅគឺវាជ្រុះចោលឡើង ៥រឺក៏៨ស្លួងជ្រុះចោលចឹងទៅបាទ៕

ក៖ បាទហើយចឹងលូវនៅមានទៀតដែលទេលោកតា???

ខ៖

បាទសំរាប់លូវនឹងគឺនៅមានតែមានតែចាស់ចាស់នោះទេបាទនិយាយទៅគឺមានគេសំបូរនឹងទិញដែលក៏ប៉ុនតែមានតែនាក់ទិញនឹងវាមានតំម្លៃនឹងវាថោកចឹងហាសបាទហើយសំរាប់មួយស្និតនឹងបាន ១៥០០៛ ដែលចឹងហាសនៅកន្លែងផ្សេងហាសបាទហើយសំរាប់ថ្ងៃសល៏នឹងបានយើងនឹងរៀងកាប់ហាសហើយនិយាយទៅគឺវាមានចេកណាដែលវាទុំមុនថ្ងៃសល៏ហាសបាទ៕

ក៖

បាទហើយចឹងបានន័យថាសំរាប់ចេកទាំងអស់នឹងគឺគេបានយកទាំងអស់ហើយមែនដែលទេលោកតា???

ខ៖

បាទសំរាប់ចេកទាំងអស់នឹងគឺគេបានយកទាំងអស់ហើយបាទហើយនិយាយទៅគឺគេទិញហើយគ្រាន់តែវាមិនទាន់ដល់ថ្ងៃចឹងហាសបាទហើយប្រសិនជាគេដល់ថ្ងៃដែលវាទុំនឹងគឺគេនឹងមកកាប់ហើយគេនឹងដាក់វានឹងទៅលើកង់៣ចឹងហាសបាទហើយគឺគេកាប់ដោយខ្លួនរបស់គេហើយនឹងរាប់ដោយខ្លួនរបស់ចឹងទៅហាសបាទ៕

កៈ
បាទើហើយចឹងសំរាប់ខ្ញុំនឹងគឺខ្ញុំគ្មានអ្វីច្រើនទេលោកតាហើយចឹងមួយសំណួរដែលខ្ញុំចង់សួរលោកតាចុងក្រោយបំផុងហើយចឹងថាតើលោកតាមានពាក្យពេជ្រអ្វីដែលផ្ដែលផ្ដាំទៅកូនចៅរបស់លោកតាដែលរឺទេនៅពេលដែលកូនចៅរបស់លោកតាបានលឺសំលេងរបស់លោកតាដែលមានភាពលំបាក់ដែលនៅក្នុងជំនាន់ពោលពតនឹងថាតើផ្ដែលផ្ដាំទៅកូនចៅរបស់លោកតាដែលរឺទេហើយនៅពេលដែលគាត់បានលឺសំលេងរបស់លោកតាអាចអោយគាត់នឹងបានយកគំរូហើយនឹងអនុវត្តនៅក្នុងជីវិតដើម្បីអោយគាត់មានភាពល្អប្រសើរនៅក្នុងសង្គមហើយអាចអោយគាត់នឹងអាកែប្រែជីវិតរបស់គាត់យ៉ាងមិចយ៉ាងមិចចឹងថាលោកតាមានពាក្យពេជ្រអ្វីផ្ដែលផ្ដាំទៅកូនចៅរបស់លោកតាដែលរឺទេលោកតា???

ខៈ
បាទសំរាប់ខ្ញុំនឹងប្រសិនជាខ្ញុំនឹងនិយាយទៅគឺនិយាយទៅច្រើនទៅវាហាត់សំរាប់ក្មេងល្ងវនឹងហើយនឹងកូនល្ងវនេះគឺមិនងាយនោះទេគឺមិនងាយនឹងស្ដាប់យើងនោះទេបាទនិយាយទៅគឺមិងាយតែម្ដងហាសបាទហើយសំរាប់សព្វថ្ងៃនឹងនៅពេលដែលយើងនិយាយ១០ម៉ាត់នឹងគឺមិននឹងស្ដាប់យើងបានតែមួយម៉ាត់ផងហាសវាទៅជាស្ដាប់ការជល់មាន់ហើយនឹងវាស្ដាប់កាក៉ាអូខេចឹងទៅបាទពួកទៅជាស្ដាប់ចឹងទៅវិញហើយប្រសិនជាយើងនឹងនិយាយចឹងទៅគឺពួកវាបាននិយាយថាយើងនឹងគឺជាមនុស្សចាស់កំរ៉ាល់ហើយសំរាប់ចាស់កំរ៉ាល់នឹងគឺបានកំរ៉ាល់រាល់ថ្ងៃនឹងទេបាទហើយសំរាប់ដីធ្លីដីផ្ទះហើយនឹងបានទិញម៉ូតូប្រសិនជាពួកវានឹងប្រសិនជារកទិញឡានហើយនឹងម៉ូតូនឹងហើយនឹងផ្ទះនឹងវាគ្មានទិញបាននោះទេបាទហើយលក់ផ្ទះបានមួយកន្លែងនឹងបាន ៥០,០០០$ រឺក៏ ៣០,០០០$ រឺក៏ ២០,០០០$ នឹងហើយបាទហើយប្រសិនជាបានហើយនឹងកុំភ្លេចគុណអីបាទនឹងហើយក៏ប៉ុនតែប្រសិនជាយើងនិយាយទៅពួកវាហើយចឹងក៏ពួកវានឹងមិនស្ដាប់យើងដែលហាសបាទ៕

កៈ
បាទហើយចឹងលោកតាអាចផ្ដែលផ្ដាំទៅកូនចៅរបស់លោកតាគាត់ថានៅពេលដែលពួកគាត់បានលឺសំលេងរបស់លោកតាហើយអីចឹងសូមអោយគាត់ចេះកែប្រែចរិតរបស់គាត់ចេះកែប្រែអោយគាត់បានគោរពលោកតាហើយនឹងដឹងគុណរបស់លោកតាដែលរឺទេលោកតា???

ខៈ
បាទសំរាប់ខ្ញុំគឺខ្ញុំផ្ដែលផ្ដាំទៅកូនចៅរបស់ខ្ញុំដែលតែពួកវានឹងមិនស្ដាប់យើងនោះទេពួកវានឹងគ្រាន់តែបាទបាទតែពីមុខរបស់យើងនោះទេហើយប្រសិនជានិយាយភូមិសុខភូមិបុណ្យអីនឹងទេសស្នាម៉ែឪតែសំរាប់កូនកូននឹងគឺពួកវានឹងមិនបានដឹងនោះទេក៏ប៉ុនតែនឹងខឹងម្ដាយហើយនឹងឪពុកក៏ប៉ុនតែគួរណាតែអាសូស្ដាប់អើយដែលមិនគប្បីដូចជារសាប់រសូនអោយចេះទុក្ខចេះដាក់នៅក្នុងធរណីទុកភេចៅទុកដើមហើយនឹងសំរាប់ទូមានកូនចៅអោយបានចៅចេះល្អហើយនឹងបានឆ្នោមកុំអោយគេនឹងខ្ពើមចឹងហាសបាទនឹងហើយកុំអោយសប្បាយនឹងវាភ្លេចខ្លួនពេកហើយនៅពេលដែលដល់ពេលយប់ព្រលប់នឹងអោយចេះទុកចេះដាក់

ហើយសូមអ្នកផងទាំងឡាយធ្វើអ្វីនឹងហាសបាទហើយសំរាប់ខ្ញុំចង់សួរក្មួយឯងថាប្រសិនជាយើមើលទៅទោសផ្ទែកអ្នកជិតខាងនឹងថាតើក្មួយឯងនឹងទោរួចដែលរឺទេនិយាយទៅគឺមិនល្អនោះទេហើយវាមិនល្អនឹងនៅត្រង់ថាសំរាប់អ្នកជិតខាងដែលខំប្រឹងធ្វើការងារទាំងយប់ហើយនឹងទាំងថ្ងៃនឹងសំរាប់គេគឺគេបានអស់កំលាំងគេហើយគេហើយនៅពេលដែលយប់ព្រលប់គឺដើរស្រុតទៅលិចហើយនឹងទៅកើតចឹងទៅទាំងអសនឹងគឺវាមិននឹងមិនមករករឿងយើងនោះទេក៏ប៉ុនតែនឹងសំរាប់ឆ្កែនឹងវាព្រុសមកវាដេកមិនបានតែម្តងហាសបាទនិយាយទៅពេញទាំងភូមិតែម្តងគ្មាននាក់ណាដេកបាននោះទេបាទហើយនិយាយទៅនឹងហើយដែលនិយាយថាទោសភ្នែកអ្នកផងទាំងឡាយហាសបាទហើយសំរាប់យើងមើលទៅគេដែលគេជាអ្នកមានក្មួយគឺគេមានបានមានប្រាក់ចាយគឺគេខំប្រឹងគេធ្វើការងារនឹងស្តាប់ធម៏ទេសស្នារបស់មាតាហើយនឹងបិតាផងហើយប្រសិនជាកូននឹងបានស្តាប់ហើយនោះនឹងហើយសូមអោយបាលីហើយនឹងទេវរូបរូបនោះខាងទេវតាទាំងអស់សូមអោយជួយថែរក្សាយើងទាំងអស់គ្នាបាទហើយនឹងសូមអោយទូមានហើយនឹងកុំអោយមានការបន្ទុះសារាយហើយសំរាប់ទេវតាដែលនៅខាងកើតនឹងដែលបានដឹងឈ្មោះនឹងហាសហើយនឹងសំរាប់ថ្ងៃនឹងហាសបាទហើយសំរាប់ម្តាយដែលយើងនិយាយទៅពួកគេមិនដែលបានស្តាប់នឹងប៉ាងព្រឹបប៉ាងព្រឹហើយទាំងអស់នឹងហើយដែលគេបានសាយតាមវិទ្យុនឹងប៉ាងព្រឹបដែលបានស្លាប់មាន៥នាក់រឺក៏៤នាក់រឺក៏៣នាក់នឹងរាល់ថ្ងៃនឹងគឺដោយសារអ្វីដោយសារតែពួកគេនឹងមិនបានស្តាប់ម្តាយហើយនឹងឪពុកនឹងហើយបានជាពួកវានឹងនៅពេលដែលពួកវាបានបើកម៉ូតូនឹងគឺវាមិនដែលបានបើកនឹងធម្មតានោះទេគឺបើកសុទ្ធតែបង់ហោះហើយពួកវានឹងឆាបយើងចឹងទៅបាទហើយអានឹងហើយហេតុអ្វីបានជាអ្វីបាទទាំងអស់នឹងមកពីពាក្យដែលគេបានប្រមាតតែមួយម៉ាត់ចឹងហាសនឹងហើយដែលពួកវានឹងមិនបានស្តាប់ម្តាយហើយនឹងឪពុកនឹងហើយបានជាពួកគេនឹងហើយមានអាយុខ្លីចឹងហាសបាទហើយសំរាប់ក្មួយក្មួយល្អណាស់ហើយប្រសិនជាខ្ញុំនិយាយមួយល្ងាចនឹងគឺនិយាយមិនអស់នោះទេគឺមានច្រើនណាស់បាទហើយសំរាប់ខ្ញុំគឺខ្ញុំបានស្រឡាញ់ហើយនឹងពាក្យហើយពាក្យទាំងអស់នឹងមាននៅក្នុងវិទ្យុនឹងគឺមិនចង់និយាយាទេយើងគួរតែអាសូរចិត្តនឹងហាសបាទគួរណាអាសូរអាណិតម្តាយដែលគាត់បានខំប្រឹងចាញ់កូនហើយនឹងចាញ់ស្លូវញ្ញរដីអាត្រៃស្មើនឹងជីវិតនឹងហាសបានស្រឡាញ់ហើយនឹងចេះគោរពហើយទទឹងនឹងខែហើយខែនឹងមកជិតហើយនឹងបានឃើញបិទពិសីហើយឃើញម្តាយឆ្លងទន្លេរហើយនឹងបានឃើញម្តាយឈឺណាស់គឺឈឺណាស់ពេញបូរមីស្រែកដូចមន្ទីនីរង់ចាំហើយសំរាប់ម្តាយបានឆ្លងបានលាភធំម្តាយហើយនឹងបានចាំសំលេងរបស់កូនហើយនឹងផ្តាំភោលកូនពិតហើយសំរាប់ម្តាយខំប្រឹងចិញ្ចឹមកូនដោយក្តីបីបាច់នៅក្នុងប្រណិតចង់កាត់ដោយរហិតជិតអោរ៉ាដល់ថ្លៃថ្លាហើយប្រសិនជាយើងនិយាយទៅវាកាន់តែវែងវែងទៅចឹងហាសបាទហើយប្រសិនជាអ្នកដែលបានស្តាប់ទៅគឺគេមិនចង់ទៅណានោះទេហើយប្រសិនគឺគេអង្គុយចង់ស្តាប់តែម្តងហាសបាទហើយសំរាប់ខ្ញុំនៅពេលដែលខ្ញុំបានជិះម៉ូតូទៅហាសហេហេហេហេហេគឺគេតែងតែហៅខ្ញុំនឹងបានចូលទៅហាសគឺចូលទៅនិយាយអំពីច្បាប់ទំលាប់ហើយនឹងកំណាព្យកាបគួននឹងហាសគឺគេចូលចិត្តតែម្តងហាសបាទគឺកំណាព្យកាបគួននឹងនិយាយដាក់នឹងវត្តចឹងទៅបាទតាមម៉ូតូអីចឹងទៅដែលនៅក្នុងភូមិ

គេមានហាសបាទនិយាយទៅគឺល្អណាស់បាទរួចហើយប្រសិនជាពើងអីនឹងទៅជាចោលម្តាយហើយនឹងដាក់តាមផ្លូវចឹងហើយយើងមិនដឹងជាយ៉ាងមិចនោះទេសំរាប់ម្តាយនឹងខំប្រឹងចិញ្ចឹមកូនហើយសំរប៉ាខ្ញុំនិយាយពីបទមិញនឹងហាសបាទសំរាប់បានតែមួយឃ្លាហើយនឹង២ឃ្លានឹងហាសហើយប្រសិនជាយើងនិយាយទៅគឺវាពីរោះនឹងស្តាប់ខ្លាំងណាស់ហើយនិយាយកន្លះម៉ោងរឺក៏១ម៉ោងទៀតក៏មិនអស់ដែលចឹងហាសបាទ៕

ក៖

បាទនឹងហើយដោយសំរាប់ខ្ញុំគឺខ្ញុំមិនដែលបានលឺចឹងហាសហើយនៅពេលដែលខ្ញុំបានលឺហើយចឹងគឺខ្ញុំមានអារម្មណ៍ថាវាមានជក់ចិត្តហាសបាទ៕

ខ៖

បាទនិយាយទៅគ្រាន់តែខ្ញុំនិយាយពីបទមុននឹងហាសហើយប្រសិនជានិយាយទៅគឺមួយម៉ោងអីនឹងបានវាចប់ហាសបាទនិយាយទៅគឺមានរឿងច្រើនណាស់ណាហើយប្រសិនជានិយាយពីធម៌របស់ព្រះពុទ្ធនឹងហើយហើយយកទៅអោយគេបានស្តាប់ហាសគឺគេនឹងចូលចិត្តហើយគេនឹងមិនទៅណានោះទេបាទគឺគេចាំតែស្តាប់នោះទេបាទគឺគេនឹងអង្គុយចាំស្តាប់តែម្តងហាសបាទហើយសំរាប់មួយច្បាប់ទៀតរឹកតែល្អទៀតបាទនិយាយទៅគឺទាំងអស់នឹងមាន៣ច្បាប់គឺនិយាយមិនអស់នោះទេបាទនឹងហើយបាទពីព្រោះអីនឹងកាល់ដែលខ្ញុំនឹងនៅរៀននឹងគឺថាគឺគេមានរៀនធម៌រៀនអាអីចឹងបាទហើយដល់ពេលដែលមានការងារអីចឹងទៅគឺគេតែងតែហៅយើងទៅហើយបាទហើយនៅពេលដែលគេបានហៅយើងចឹងទៅគឺគេតែងតែជូនលុយជូនកាក់អោយយើងចឹងទៅមានពេលខ្លះនឹងបាន ១០០០០៛ ចឹងទៅហើយមានពេលខ្លះនឹងបាន ៥០០០៛ចឹងទៅបាទ៕

ក៖

បាទហើយចឹងសំរាប់ខ្ញុំនឹងគឺខ្ញុំមានអារម្មណ៍ថាសប្បាយចិត្តមែនទែនហើយក៏អរគុណសំរាប់ការមានពិភាក្សាហើយនឹងបានប្រាប់ពីជីវិតពិតរបស់លោកតានៅក្នុងជំនាន់ពោលពតដែលលោកតាបានជួបបញ្ហាលំបាក់ច្រើនរបស់លោកតាហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំអត់សួរមានអ្វីច្រើនសំរាប់លោកតានោះទេមានតែប៉ុននឹងហើយចឹងសំរាប់លោកតាមានអ្វីផ្តែលផ្តាំអ្វីបន្ថែមទៀតទេដែលជាពាក្យចុងក្រោយមានអ្វីដែលរឺទេលោកតារឺក៏លោកតាចង់បញ្ចប់រឺក៏យ៉ាងដែលទៅលោកតា???

ខ៖

បាទបញ្ចប់ទៅបាទហេហេហេហេបាទពីព្រោះអីនឹងវាខ្វះតែ១៨នាទីទៀតនោះទេគឺវា១ម៉ោងហើយបាទហើយសំរាប់ម៉ោង៣នឹងគឺខ្ញុំត្រូវទៅមានការបន្តិចហាសបាទហើយគឺខ្ញុំនឹងទៅដឹងបន្លែរទៀតហាសបាទ៕

ក៖

បាទហើយចឹងអរគុណច្រើនមែនទែនលោកតាហើយចឹងហើយសំរាប់សប្បាយចិត្តមែនហើ

យក៏ខ្ញុំអរគុណលោកតាម្តងទៀតហើយអរគុណច្រើនម្តងទៀតបាទហើយចឹងចៅសុំជំរាបលាណាលោកតា៕